BBI0091

# សម្ភាសន៍ជាមួយឈ្មោះ ស៊ុម ម៉ាលី ភេទប្រុស អាយុ៦៤ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានក្រុមគ-១៨ខាងកាំភ្លើងធំ តំបន់២

មុខងារបច្ចុប្បន្នៈ មេភូមិភ្នំព្រឹក្ស

ស្រុកកំណើតនៅភូមិត្រពាំងធំ ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិភ្នំព្រឹក្ស ឃុំភ្នំព្រឹក្ស ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបង

ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០១:១៥:២០

៤១ទំព័រ

ដានី : បាទ! ដំបូងចង់ស្គាល់ឈ្មោះអ៊ំៗឈ្មោះពេញឈ្មោះអីដែរ?

ម៉ាលី : ឈ្មោះ ស៊ុម ម៉ាលី ។

ដានី : បាទ?

ម៉ាលី : ស៊ុម ។

ដានី : ស៊ុម ម៉ាលី?

ម៉ាលី : បាទ!

ដានី : អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

ម៉ាលី : អាយុ៦៤ហើយ ។

ដានី : ស្រុកកំណើតកើតជាអ៊ំនៅណាទៅ?

ម៉ាលី : កើតនៅស្រុកតាកែវ ត្រាំកក់ ។

ដានី : ភូមិអីគេ?

ម៉ាលី : ភូមិត្រពាំងធំ ឃុំត្រពាំងធំ ឥឡូវសរសេរដាក់ ក្នុងស្រុកត្រាំកក់ ។

ដានី : ខេត្តតាកែវ?

ម៉ាលី : ខេត្តតាកែវ ។

ដានី : សព្វថ្ងៃអ៊ំរស់នៅភូមិឃុំអីដែរ?

ម៉ាលី : បាទ! សព្វថ្ងៃខ្ញុំរស់នៅភូមិភ្នំព្រឹក្ស ឃុំភ្នំព្រឹក្សដែរ ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបង ។

ដានី : គ្រួសារអ៊ំ ប្រពន្ធអ៊ំឈ្មោះអីដែរ?

ម៉ាលី ៖ ឈ្មោះ យឹម ម៉ាន់ ។

ដានី ៖ យឹម ម៉ាន់?

ម៉ាលី ៖ បាទ!

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

ម៉ាលី ៖ ចូល៦០ដែលនឹង ។

ដានី ៖ ៦០ដាង?

ម៉ាលី ៖ បាទ!

ដានី ៖ គាត់អ្នកស្រុកកំណើតនៅណាដែរ?

ម៉ាលី ៖ យាយខ្ញុំ(ប្រពន្ធ) ស្រុកកំណើតនៅត្រពាំងធំដូចគ្នា ។

ដានី ៖ នៅភូមិឃុំជាមួយគ្នាម៉ង?

ម៉ាលី ៖ បាទ!

ដានី ៖ អ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

ម៉ាលី ៖ កូន៤នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ម៉ាលី ៖ ស្រី២ ប្រុស២ ។

ដានី ៖ ធំៗអស់ហើយ?

ម៉ាលី ៖ ធំអស់ហើយ កូនពៅអាយុ២០ ប៉ុនអត់ទាន់មានប្រពន្ធទេ ។

ដានី ៖ អ៊ំសព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

ម៉ាលី ៖ ធ្វើចំការប្អូន ។

ដានី ៖ ធ្វើចំការធ្វើអីខ្លះ?

ម៉ាលី ៖ ដាំដំឡូងៗមី ដាំពោត ។

ដានី ៖ ចុះអ៊ំចឹងធ្វើចំការធ្វើដំឡូងមីង ធ្វើពោត អត់មានធ្វើស្រូវ ដាំស្រូវ?

ម៉ាលី ៖ អត់មានដីដាំស្រូវទេ តំបន់ភ្នំម៉ងយើង តាមជើងភ្នំនឹង ។

ដានី ៖ ហ្នឹងអ៊ំធ្វើមេភូមិតាំងពីអង្កាល់មក?

ម៉ាលី ៖ តាំងពី៩១នឹងមក ។

ដានី ៖ ៩១អ៊ំធ្វើមេភូមិភ្នំព្រីក្សនឹង?

ម៉ាលី ៖ បាទ! នៅភ្នំព្រីក្សនឹង ចេញពីដីថៃមកនៅនឹង ។

ដានី ៖ ចុះអ៊ំ ឪពុកម្ដាយ ឪពុកអ៊ំគាត់ឈ្មោះអីដែរ?

ម៉ាលី ៖ ឈ្មោះ ស៊ុម ។

ដានី ៖ សព្វថ្ងៃគាត់ខូចហើយ?

ម៉ាលី ៖ ស្លាប់បាត់ហើយ ។

ដានី ៖ គាត់ខូចតាំងអីអន្លាល់?

ម៉ាលី ៖ តាំងពីឆ្នាំ៧០ ។

ដានី ៖ តាំងពីឆ្នាំ៧០?

ម៉ាលី ៖ ៧៣ ខ្ទង់៧៣ហើយ ។

ដានី ៖ ៧៣ គាត់ស្លាប់ដោយសារជម្ងឺ ឬក៏ម៉េច?

ម៉ាលី ៖ បើប្រវត្តិដែលខ្ញុំចុះទៅជួបគាត់ ដែលខ្ញុំនៅបាត់ដំបងចុះជួបគាត់ៗថាគាត់អត់ហូបបាយម៉ង ពុកខ្ញុំ គាត់ស្លាប់មិនហូបបាយម៉ង គាត់មិនដឹងជាមូលហេតុអីគាត់ ។

ដានី ៖ គាត់អត់ហូបបាយនឹង មូលហេតុគាត់មានសតិអារម្មណ៍?

ម៉ាលី ៖ បាទ! គាត់មានសតិអារម្មណ៍មួយ ប៉ុនអត់ដឹង ។ បានថាគាត់ព្រួយបារម្ភគាត់ វាកូនចៅ៣ឆ្នាំនឹង ។ អានឹងបាយរួមៗឆ្នាំ៧៣យើងនឹង មើល!៧៣កំពុងសង្គ្រាម ៧៥ អូយ!មិញខ្ញុំសប្អូន វាចូលរួមបាយហើយនឹង៧៦ ៧៧នឹងហើយ បាយរួមហើយនោះ ។

ដានី ៖ ចុះម្ដាយអ៊ំ?

ម៉ាលី ៖ ម្ដាយគាត់ស្លាប់ដោយជម្ងឺធម្មតាទេ ដល់ស្រុកយើងចេះហើយទេ ។

ដានី ៖ បាទ! ម្ដាយអ៊ំឈ្មោះអីគេ?

ម៉ាលី ៖ ឈ្មោះ សឹង ។

ដានី ៖ ស្លាប់ឆ្នាំណាដែរ?

ម៉ាលី ៖ អឺ! ស្លាប់២០០០ប៉ុន្មានទេ ។

ដានី ៖ ឆ្នាំ២០០០ជាងហើយ?

ម៉ាលី ៖ បាទ! ២០០០ជាង ២០០៣លើសតិចតួច ។

ដានី ៖ ចុះបងប្អូនអ៊ំបង្កើតមានប៉ុន្មាននាក់ដែរ?

ម៉ាលី ៖ បងប្អូនខ្ញុំមាន៥-៦នាក់ ឈប់ៗភ្លេច បងប្អូនច្រើនពេក ៥-៦ នៅ៥នាក់ ។

ដានី ៖ ៥នាក់?

ម៉ាលី ៖ បាទ!

ដានី ៖ ស្រីប៉ុន្មាន ប្រុស?

ម៉ាលី ៖ ស្រី២ៗ ។

ដានី ៖ ស្រី២ ប្រុស៣?

ម៉ាលី ៖ បាទ!

ដានី ៖ អ៊ំកូនទីប៉ុន្មាន?

ម៉ាលី ៖ ខ្ញុំកូនទី២ ។

ដានី ៖ កាលពីនៅក្មេងៗ អ៊ំបាននៅរៀនសូត្រដល់ណាដែរ?

ម៉ាលី ៖ ខ្ញុំនៅរៀនបឋមសិក្សា ថ្នាក់ទី៧ចាស់ពីដើម ។

ដានី ៖ រៀននៅសាលាណា?

ម៉ាលី ៖ រៀននៅត្រពាំងធំនឹងម៉ង កាលនឹងថ្នាក់ទី៧នៅស្រុកយើង ។

ដានី ៖ បាទ! រៀននៅត្រពាំងធំ អ៊ំរៀនត្រឹមថ្នាក់ទី៧អ៊ំឈប់?

ម៉ាលី ៖ បាទ! ឈប់ ។

ដានី ៖ ឈប់ឆ្នាំណា អ៊ំចាំទេ?

ម៉ាលី ៖ អួយ! កាលនឹង៦៧ ដែលខ្ញុំចេញពីនឹងមកនេះ ឈប់ហើយខ្ញុំចេញមកនេះ ១៩៦៧ ។

ដានី ៖ ១៩៦៧ ឈប់ហើយអ៊ំចេញទៅណា?

ម៉ាលី ៖ ឈប់ហើយខ្ញុំមក ម្ដាយខ្ញុំមកពោធិ៍សាត់ ខ្ញុំមកពោធិ៍សាត់ គាត់មករកស៊ីនៅពោធិ៍សាត់ នេះ គាត់ចាប់ដីស្រែនៅពោធិ៍សាត់ ។

ដានី ៖ មកពោធិ៍សាត់ មកជាមួយម្ដាយឪពុក?

ម៉ាលី ៖ បាទ!

ដានី ៖ គ្រួសារអ៊ំមកទាំងអស់គ្នា ក៏មកម្ដាយ?

ម៉ាលី ៖ កាលនោះអត់ទាន់មានគ្រួសារទេ កាលនោះទើបនឹងឈប់រៀន ។

ដានី ៖ ឈប់រៀនហើយមកនៅជាមួយម្ដាយ?

ម៉ាលី ៖ បាទ! ហ្នឹងហើយ

ដានី ៖ ឪពុកមកដែរ?

ម៉ាលី ៖ ឪពុកមកៗទាំងម្ដាយឪពុក មកស្លាប់នៅពោធិ៍សាត់ ។

ដានី ៖ ចឹងផ្លាស់មកម៉ង ផ្លាស់ពីត្រពាំងធំមកនៅពោធិ៍សាត់មក?

ម៉ាលី ៖ មកៗ ។

ដានី ៈ មកពោធិ៍សាត់ មកនៅកន្លែងណាទៅ?

ម៉ាលី ៈ នៅមុំបាកាន ប្អូនដែរចូលទេ ។

ដានី ៈ ភូមិអី ឃុំអី?

ម៉ាលី ៈ នៅភូមិព្រះចំបក់ ដំណាក់កន្សែង ។

ដានី ៈ ភូមិអីគេ?

ម៉ាលី ៈ ព្រះចំបក់ ។

ដានី ៈ ព្រះចំបក់ អឺ!ដំណាក់ ។ ឃុំអីគេ?

ម៉ាលី ៈ ឃុំបាកានអានឹង ។

ដានី ៈ ឃុំបាកាន ស្រុកបាកាន?

ម៉ាលី ៈ ស្រុកបាកាន ។

ដានី ៈ ខេត្តពោធិ៍សាត់?

ម៉ាលី ៈ ខេត្តពោធិ៍សាត់ អានឹងនៅនឹង ។

ដានី ៈ បាទ! ចឹងទាំងបងប្អូនមកនៅនឹងទាំងអស់គ្នា មកនៅនឹងទាំងអស់?

ម៉ាលី ៈ ទាំងអស់ ។

ដានី ៈ ចុះមកដល់ពោធិ៍សាត់ អ៊ំធ្វើអីទៀតទៅ?

ម៉ាលី ៈ មកដល់ពោធិ៍សាត់ ខ្ញុំធ្វើស្រែ ។

ដានី ៈ ធ្វើស្រែរហូតដល់ពេលណា?

ម៉ាលី ៈ ធ្វើស្រែដល់ឆ្នាំ១៩៧០ ខ្ញុំទៅធ្វើចំការនៅភ្នំក្រវាញ់ ។ នឹងទៅតែខ្ញុំទេ ទៅតែគ្រួសារ២ នាក់ប្ដីប្រពន្ធប៉ុននឹង ។ នឹងការបានប្រពន្ធនៅនឹង ស្រុកដូចគ្នា ។

ដានី ៈ មកធ្វើស្រែនៅភ្នំក្រវាញ់?

ម៉ាលី ៈ ធ្វើចំការ ភ្នំក្រវាញ់ ។

ដានី ៈ ធ្វើចំការនៅភ្នំក្រវាញ់?

ម៉ាលី ៈ បាទ!

ដានី ៈ កាលនឹងអ៊ំរៀបការឆ្នាំណា?

ម៉ាលី ៈ ឆ្នាំ៧០មានប្រពន្ធហើយ បើការ នឹងហើយ៦៧ ៦៨នឹង ។

ដានី ៈ រៀបការឆ្នាំណា?

ម៉ាលី ៈ ដាក់៦៨ អឺ!៦៩យើងទៅ៧០ កាលនោះ៦៩ ។

ដានី ៈ អ៊ំរៀបការនៅណា?

ម៉ាលី ៈ ការនៅពោធិ៍សាត់ ។

ដានី ៈ ការនៅពោធិ៍សាត់ ចឹងគ្រួសារ ខាងប្រពន្ធអ៊ំគាត់ផ្លាស់មកពោធិ៍សាត់ដែរ?

ម៉ាលី ៈ បាទ! មកពីនឹងដែរ សុទ្ធតែអ្នកមករកស៊ីនឹងដែរនឹង ៧០ មកនៅជាមួយ ។

ដានី ៈ ចឹងកាលនឹងអ្នកនៅភូមិធំ ត្រពាំងធំមកពោធិ៍សាត់ច្រើន?

ម៉ាលី ៈ មកច្រើន ។

ដានី ៈ មកប៉ុន្មានទៅ?

ម៉ាលី ៈ ហ៊ើ! មកច្រើនគ្រួសារណាស់ មានបងខ្ញុំជីដូនមួយក៏មក កាលនឹងអីឈ្មោះប៉ែ គួបៗ គាត់អ្នកនាំមកមុនគេ គាត់ប្អូនតាម៉ុក ។

ដានី ៈ បាទ?

ម៉ាលី ៈ គាត់ប្អូនតាម៉ុក ប៉ែ គួបៗ ប្អូនតាម៉ុក កាលនឹងគាត់អ្នកនាំមកនៅស្រុកនឹង គាត់ទិញដីស្រែ ។

ដានី ៈ ប្អូនតាម៉ុក គាត់ឈ្មោះអីគេ?

ម៉ាលី ៈ យាយគួប មិនដឹងយាយគួប យាយកេននឹងម៉ាដួរនឹង ។

ដានី ៈ យាយគួបនឹងត្រូវប្អូនតាម៉ុក ហើយក៏បង?

ម៉ាលី ៈ ប្អូន ។

ដានី ៈ ប្អូនបងយាយកេននឹង?

ម៉ាលី ៈ នឹងបង ។

ដានី ៈ បងយាយកេន?

ម៉ាលី ៈ នឹង ។

ដានី ៈ យាយកេន គាត់ប្រពន្ធរបស់?

ម៉ាលី ៈ ហ្នឹងតាមុត មិនដឹងប្រពន្ធអ្នកណានេះ ។

ដានី ៈ ប្រពន្ធតាទិត?

ម៉ាលី ៈ អត់ទេ យាយកេនៗ មិនមែនទេ ប្រពន្ធតាទិត មិនមែនកូនតាម៉ុកទេ ។

ដានី ៈ ប្អូន?

ម៉ាលី ៈ ហ្នឹងហើយប្អូន មិននេះទេ មិនមែនប្អូនបង្កើតទេ កូនតាបែមៗ ខ្ញុំភ្លេចយូរវាខ្ញុំប្លែកយូរគ្នាហើយ សុទ្ធតែជីដូនមួយគ្នា ។

ដានី ៖ ប៉ុន្តែប្អូនជីដូនមួយអីដែរ?

ម៉ាលី ៖ ហ្នឹងហើយ ចុះស្រែជាប់គ្នា ។

ដានី ៖ ចឹងយាយជួបហើយនឹងអី?

ម៉ាលី ៖ យាយតួបនឹងជីដូនមួយដែរ បងៗជីដូនមួយ ។

ដានី ៖ បងជីដូនមួយ?

ម៉ាលី ៖ បងប្អូនជីដូនមួយ ។ ចឹងខ្ញុំមកនៅនឹងដោយសារ គាត់នឹង គាត់អ្នកមកមុនគេ ម៉ែខ្ញុំមកតាមគាត់ ហើយខ្ញុំក៏ឈប់រៀនមកនឹងដែរមក ។

ដានី ៖ ដល់ពេលចឹង ដល់ពេលអីរៀបការ?

ម៉ាលី ៖ បានប្រពន្ធ បានខ្ញុំទៅធ្វើការនៅភ្នំក្រវ៉ាញ ។

ដានី ៖ ប្រពន្ធអីនឹងត្រូវជាសាច់ញាតិអីដែរ អត់ទេ?

ម៉ាលី ៖ អត់ទេ មានអ្នកជិតខាង អ្នកភូមិគេ នៅបៀតៗគ្នា បានខ្ញុំទៅធ្វើចំការនៅភ្នំក្រវ៉ាញ ។

ដានី ៖ យាយតួប គាត់មកនៅនឹង គ្រួសារគាត់មកនៅនឹងដែរ?

ម៉ាលី ៖ គ្រួសារមកនៅនឹងដែរ ។

ដានី ៖ អត់ទេ កាលនៅពោធិ៍សាត់?

ម៉ាលី ៖ នៅពោធិ៍សាត់ នឹងគាត់មកនៅនឹងដែរ ។

ដានី ៖ អូ! មកនៅពោធិ៍សាត់ដែរ មកនៅមុន?

ម៉ាលី ៖ នៅមុនខ្ញុំ ។

ដានី ៖ នៅមុន?

ម៉ាលី ៖ ....មិនមែនមកទេ មកពោធិ៍សាត់ ។

ដានី ៖ ចុះសព្វថ្ងៃគាត់ខូច ហើយនៅ?

ម៉ាលី ៖ ប្ដីគាត់ស្លាប់តាំងពីយូរហើយ ប៉ុនដឹងគាត់មិនដឹងជានៅណា នៅប៉ៃលិន ហើយនៅណា ។

ដានី ៖ ចឹងអីមកធ្វើចំការនៅពោធិ៍សាត់ កាលនឹងមកគ្រួសារអីប្ដីប្រពន្ធ?

ម៉ាលី ៖ កាលហើយនោះ ខ្ញុំមកជាមួយម្ដាយខ្ញុំ មកនៅធ្វើស្រែនៅពោធិ៍សាត់ ។ ចឹងបានខ្ញុំមានគ្រួសារ បានខ្ញុំទៅនៅភ្នំក្រវ៉ាញឆ្នាំ១៩៧០នឹង ភ្នំក្រវ៉ាញធ្វើចំការ ។ ខ្ញុំបានធ្វើចំការមិនទាន់បានម៉ាឆ្នាំស្រួលផងនឹង រដ្ឋប្រហារ ។

ដានី ៖ ចឹងធ្វើមិនទាន់បានម៉ាឆ្នាំផង ដល់ឆ្នាំ៧០?

ម៉ាលី ៖ ៧០ ថ្ងៃប៉ុន្មាន កំពុងកាប់សសរផ្ទះយើងលើកផ្ទះនឹង ធ្វើរដ្ឋប្រហារបណ្ដោយ ។

ដានី : បាទ! ដល់ពេលរដ្ឋប្រហារនឹងយ៉ាងម៉េចទៀតអ៊ំ?

ម៉ាលី : រដ្ឋប្រហារ កាលនឹងមានខ្មែរក្រហមគេបំផុសបំផុលអីនឹងណា ចូលមកថាចូលព្រៃម៉ាក់គី យើងចូលនឹងគេ ចូលធ្វើទាហាននឹងគេទៅ។ ចាប់ផ្ដើមចូលធ្វើទាហាន ចោលប្រពន្ធហើយណា។

ដានី : អូ! កាលនឹងអ៊ំចោល?

ម៉ាលី : ចោលហើយមានស្អី បែកទៅហើយ ជូនប្រពន្ធមកឲ្យម៉ែនៅពោធិ៍សាត់វិញ។ មានអីអានឹងធ្វើរហូត ចាប់ធ្វើចល័តទាហានរហូត។

ដានី : ដល់ពេលចឹងអ៊ំទាហានខាង?

ម៉ាលី : រណសិរ្ស។

ដានី : រណសិរ្សនឹង នៅឆ្នាំ៧០ នឹងម៉ង?

ម៉ាលី : បាទ! ចាប់៧០។

ដានី : ហើយប្រពន្ធអ៊ំបញ្ជូនមកពោធិ៍សាត់?

ម៉ាលី : មកនៅជាមួយម្ដាយ។

ដានី : ហើយកាលនឹងអ៊ំមានកូននៅ?

ម៉ាលី : អត់ទាន់មានទេ។

ដានី : នៅទេ។ ចឹងអ៊ំទៅធ្វើទាហាននឹងនៅណាទៅ?

ម៉ាលី : ភ្នំខ្វាវនេះម៉ង។

ដានី : នៅភ្នំខ្វាវ?

ម៉ាលី : គេហៅកងចល័តតាមភូមិនោះ។

ដានី : យើងនៅក្នុងភូមិ ហើយយើងនៅក្នុងព្រៃ?

ម៉ាលី : កងចល័តក្នុងភូមិ ប៉ុនយើងនៅក្នុងព្រៃទាហានដេញរាល់ថ្ងៃ។

ដានី : កាលនឹងអ៊ំចូលទៅជាមួយពីណាខ្លះទៅ?

ម៉ាលី : តាមប្រវត្តិ សុទ្ធតែមេធំច្រើន ប៉ុនដូចងាប់អស់ហើយ។

ដានី : ពីណាខ្លះអ៊ំចាំ?

ម៉ាលី : តាំងពីតាម៉នគាត់នៅ តាំងពីតាឡេង តាំងពី កាលនឹងបើគិតទៅមានមេខ្មែរក្រហមមួយ ខ្ញុំស្គាល់កាលនឹងតាខៀវ សំផន ទៅម្ដងដែរ ទៅដល់នឹង ទៅឃោសនា ទៅអប់រំនឹង។ បើខ្មោចតាឈើមៗ ចាស់ខ្មែរក្រហមយូរ ប៉ុនគាត់ស្លាប់បាត់អស់ហើយ។ ទៅជួបបានតា

ខៀវ សំផនម្តង, ហ៊ូ នឹមម្តង គាត់អប់រំនៅនឹង ។ ចឹងក្រោយមកយើងវៃរំដោះ វៃចុះ វៃឡើងធ្វើទ័ពបែកគ្នារហូតដល់ខ្ញុំធ្វើទ័ពជាប់មកនៅខាងក្នុងមកបាត់រយៈធំៗអស់ ។

ដានី : ចុះអ៊ំតាខៀវ សំផនទៅជាជួបអ៊ំ ឆ្នាំណា?

ម៉ាលី : អូ! អានឹងឆ្នាំ៧០ ៗដែរនឹង ទៅអប់រំកងទ័ព អប់រំអី ។

ដានី : ទៅភ្នំក្រវ៉ាញនឹង?

ម៉ាលី : បាទ! នៅភ្នំក្រវ៉ាញ គេហៅស្តង់ ។

ដានី : គេហៅអីគេ ស្តង់?

ម៉ាលី : ហ្នឹងស្តង់ ម៉ាជួរភ្នំក្រវ៉ាញនឹងហើយ ផ្កាស្តង់ ។

ដានី : កាលនឹងតាខៀវ សំផនគាត់ទៅម្នាក់ឯងទេ?

ម៉ាលី : ទៅកូនទាហានគាត់២-៣នាក់ដែរនឹង ។

ដានី : គាត់ទៅឃោសនាថាម៉េចខ្លះទៅ?

ម៉ាលី : គាត់ទៅអប់រំឲ្យតស៊ូ តាំងពីស្ត្រីពី.... គាត់ប្រសព្វលើកដែលនឹងកាលនឹង គាត់យកស្ត្រីទៅតស៊ូដែរនឹង កុំឲ្យគេថាស្ត្រីវិលចង្ក្រានមិនដុំអីនឹងតែប៉ុននឹង ។ នយោបាយអប់រំ គ្រាន់ថាឲ្យយើងបេះតស៊ូ ជំនាន់នោះ អានឹងមានប៉ុននឹង ។

ដានី : បាទ! តស៊ូជាមួយលន់ នល់?

ម៉ាលី : បាទ!

ដានី : ចុះហ៊ូ នឹម ហ៊ូ យន់ គាត់ទៅឆ្នាំណាទៀត?

ម៉ាលី : គាត់ទៅរៀបចំ កាលនឹងហ៊ូ នឹម គាត់ទៅឃើញដឹកអង្ករដឹកអីតាមព្រៃទៅ បាននិយាយច្រើនជំនាន់នោះ អត់ទាន់បានប្រជុំបានធំ ។ ដកដាក់ទាហានៗយើងបែកគ្នាភ្លែតៗ អត់មានសាច់ការណ៍អីផង ។

ដានី : ចឹងកាលអ៊ំចូលទាហានដំបូង កងទ័ពដំបូងនឹង គេហៅនៅក្នុងកងអីៗទៅ?

ម៉ាលី : អើយ! កាលនឹងមិនដឹងឈ្មោះកងអីទេ គេហៅចល័តម៉ង ។

ដានី : កងចល័ត?

ម៉ាលី : កងចល័តម៉ង ។

ដានី : គ្នាច្រើនទេ?

ម៉ាលី : គ្នា៤០នាក់នោះ មានចាម កាលនឹងមានចាម មានខ្មែរផង ។

ដានី : ពីណាគេដឹកនាំ៤០នាក់?

ម៉ាលី : អឺ! កាលនឹងតាយ៉នៗ ហើយតាឈើម ប៉ុនដឹងមួយអ្នកណាមេធំច្បាស់ មិនឃើញដែរនឹង

ដានី : គាត់នៅរស់ទេ?

ម៉ាលី : យី! បាត់អស់ហើយ ។

ដានី : គាត់ចាស់ៗហើយ?

ម៉ាលី : គាត់ចាស់ហើយ ខ្ញុំជួបគាត់កាន់កាំភ្លើងខ្លីញ៉ូរអឺនឹង ដល់ក្រោយមកគាត់បំបែកមក ពីតស៊ូនឹងមក ខ្ញុំបែកជាមួយពួកគាត់ ខ្ញុំធ្វើកងកម្លាំងខ្ញុំធ្វើកងទ័ពនៅប្រាសាទ ។

ដានី : មកធ្វើកងទ័ពនៅឆ្នាំណា?

ម៉ាលី : ដល់ឆ្នាំ៧០អើយនេះ ៧៦ ៧៧ ខ្ញុំមកនៅ ។ អឺ!មិនមែនទេតាំងពី មើលខ្ញុំគិតមើលសិន ក្នុង៧៤ ៧៥ ខ្ញុំចុះចេញពី៧៣មកនេះមក ។ ខ្ញុំមកនៅ៧៤ ៧៥នឹង ។

ដានី : ចឹង៧៣អ៊ីចុះចេញមកណា?

ម៉ាលី : មកនៅកង មកនៅធ្វើទ័ពនៅពោធិ៍សាត់ ។

ដានី : ៧៣មកហើយ?

ម៉ាលី : ហ្នឹងហើយចេញ៧៣មកហើយ ។

ដានី : មកធ្វើទ័ពនៅពោធិ៍សាត់?

ម៉ាលី : កងទ័ព បាទ!

ដានី : ទ័ពអីគេនៅពោធិ៍សាត់?

ម៉ាលី : អានឹងគេហៅថាកងតំបន់ ។

ដានី : ទ័ពពោធិ៍សាត់?

ម៉ាលី : ហ្នឹងកងតំបន់ ។

ដានី : កងតំបន់ៗប៉ុន្មាន?

ម៉ាលី : តំបន់ គេហៅតំបន់២ ។

ដានី : តំបន់២?

ម៉ាលី : បាទ!

ដានី : ម៉ាកងតំបន់២?

ម៉ាលី : បាទ! នឹងតំបន់២ ដល់ម៉ាខែក្រោយមកទៀត វាដល់៧៥បានគេបញ្ជូនខ្ញុំរៀបចំមក គេហៅថាកងភាគ ភូមិភាគ គេហៅគ-១៨ ។ អានឹងកងកាំភ្លើងធំហើយណា៎ គ-១៨ ។

ដានី : កងភាគ ភូមិភាគ គ-១៨?

ម៉ាលី ៖ គ-១៨ ។

ដានី ៖ អានឹងកងកាំភ្លើងធំ?

ម៉ាលី ៖ កងកាំភ្លើងធំ អានឹងគេយកទៅដាក់បាត់ដំបងហើយនឹង ។

ដានី ៖ កងកាំភ្លើងធំ?

ម៉ាលី ៖ ហ្នឹងកងកាំភ្លើង បើគេយកមកដាក់បាត់ដំបងហើយនឹង ។

ដានី ៖ ភាគអី ភូមិភាគអី?

ម៉ាលី ៖ ភូមិភាគពាយ័ព្យ បាទ!អានឹងកង ក្តាប់តាសាន ខាងតាឃឹមនឹង ។

ដានី ៖ ខាង?

ម៉ាលី ៖ ខាងតាសាន តាឃឹម តាកននឹងយើងនឹង ហ្នឹងហើយចាប់ព្រោងព្រៀបចឹងទៅ ។

ដានី ៖ តាញឹម តាណាទៀត?

ម៉ាលី ៖ តាញឹម តាកនៗហៅតាកឹ ។

ដានី ៖ តាកឹ?

ម៉ាលី ៖ ហ្នឹងហើយ ។

ដានី ៖ ចុះតាសាន?

ម៉ាលី ៖ តាសាន តាញឹមនឹងហើយ តាខ្វែងនឹងដឹងមានហៅអីទៀតអត់ ។

ដានី ៖ បាទ?

ម៉ាលី ៖ តាខ្វែងដឹងថាគាត់ប្រែឈ្មោះអីទៀតអត់ ដឹងថាតាខ្វែង ដឹងតែប៉ុននឹង ។ ប៉ុនទៅអន្តភាពរបស់ក្រោមធ្វើកូនទាហាននឹង ។

ដានី ៖ ចឹងកាលនឹងអ៊ំមានតួនាទីអីដែរ?

ម៉ាលី ៖ ខ្ញុំមេក្រុម នៅក្នុងក្រុមនឹង មេក្រុមកងទ័ពនឹង ត្រូវតែមានទោសគេរហូតនឹង ។

ដានី ៖ កាលនឹងអ៊ំនៅខាងកាំភ្លើងធំ គ-១៨?

ម៉ាលី ៖ បាទ!

ដានី ៖ អានឹងបែកនៅ?

ម៉ាលី ៖ ៧៥ ពេលរំដោះនឹងចូលមក ។

ដានី ៖ ៧៥ បែកភ្នំពេញ?

ម៉ាលី ៖ បែកភ្នំពេញហើយ គេបញ្ជូនយើងចូលមកក្រុងហើយ គ-១៨នឹងមករៀបចំនៅក្នុងក្រុងបាត់ដំបងហើយនឹង ។

ដានី : នៅក្នុងក្រុងបាត់ដំបង?

ម៉ាលី : ក្រុងបាត់ដំបង ។

ដានី : កាលនឹងអ៊ំនៅកន្លែងណា នៅជាមួយតាស្វែង?

ម៉ាលី : ខ្ញុំនៅខេត្តនឹងម៊ង់ នៅខេត្តមិនដឹងមេណាធំគេនោះ ។

ដានី : តាខ្វែងៗគាត់ខាងយោធា?

ម៉ាលី : ហ្នឹងតាខ្វែង ។

ដានី : តាខ្វែងខាងយោធា?

ម៉ាលី : នឹងខាងយោធានឹងហើយ តាខ្វែងនឹង ចឹងបាននៅប្រហែលប៉ុន្មានខែទេ បានគេបំបែកកងអាគ-១៨នេះ គេបំបែកខ្ញុំឲ្យនៅ២០០នាក់ទៅប៉ៃលិន នឹងមានកងវរៈគេមួយ ។ ហើយកងវរៈនឹង...(ស្តាប់មិនបាន) រំដោះរួចបាត់ ។

ដានី : ឲ្យមកប៉ៃលិនវិញ?

ម៉ាលី : ទៅប៉ៃលិន ។

ដានី : ចឹងដល់ពេលប៉ៃលិនទៅជាម៉េចវិញ ទៅជាកង?

ម៉ាលី : ទៅប៉ៃលិននឹងទៅអត់យូរទេ ប្រហែលជាកន្លះខែ ថាកន្លះខែចុះកាលនឹងខ្ញុំអត់បានគិត ។ កន្លះខែអាទ័ព២០០នឹងត្រូវដកទៀត ។

ដានី : អានឹកងរបស់អ៊ំឡើងទៅជាវរៈហើយ?

ម៉ាលី : បាទ! ឡើងវរៈហើយ ទៅជាវរៈនឹងហើយ ។

ដានី : វរៈៗគេហៅវរៈអី លេខអី?

ម៉ាលី : អឺ!យីកាលនឹងវា ដឹងវរៈលេខប៉ុន្មានទេ ប៉ុននៅហៅគ-១៨ ដដែល ប៉ុនវរៈទីប៉ុន្មានទេនេះ ខ្ញុំវាមិនចាំវរៈគេកាលនឹង ។ ប៉ុនវាអត់ទាន់មានដាក់វរៈស្រួលបួលនឹងទៅដល់ប៉ុន្មានថ្ងៃនឹង បំបែកចេញជាក្រុមទៀត ។ ខ្លះគេដកចូលបាត់ដំបង ខ្ញុំគេបញ្ជូនដាក់កំពឹងពួយបានច្បាស់ កំពឹងពួយ២០នាក់នឹងគេនៅប្រចាំការណ៍កំពឹងពួយម៊ង់ គ្មានគ គ្មានកងអីទេ ។ ដឹងថាគ-១៨ម៊ង់ កងភាគនៅនឹងម៊ង់ ។

ដានី : បាទ! ចឹងអឺ!ក្រោយមកបញ្ជូនមកកំពឹងពួយវិញ?

ម៉ាលី : បាទ! កំពឹងពួយនឹងហើយ ២០នាក់នៅនឹង នៅដល់គេ....បាញ់ផ្ទុះឆ្ងាយបាន២០ថ្ងៃដែរ ។

ដានី : កំពឹងពួយ?

ម៉ាលី : បាទ! ២០នាក់នៅនឹង ។

ដានី : ២០នាក់នឹងគេហៅអីគេ?

ម៉ាលី : អានឹងគេហៅកងភាគ ១៨ ប្រចាំការណ៍ទាំងអស់ ១៨បំបែកទៅកងភូមិភាគ ។

ដានី : កងភាគ?

ម៉ាលី : អឺ! កងភាគបាត់ដំបងនឹង ។

ដានី : កងភាគបាត់ដំបង មានតួនាទីអីខ្លះទៅ?

ម៉ាលី : គេបញ្ជូនទៅនឹងគេថាឲ្យមើលប្រជាពលរដ្ឋ វែក សែង ហើយលីនឹងប៉ុននឹង ។ ហើយខ្ញុំដឹង មើលណា ម៉ាថ្ងៃៗដើររក.....(ស្តាប់មិនបាន) ។ ធ្វើអត់កើតទេ អានឹងនៅ២០ថ្ងៃ ។ នៅកំពីងពួយនឹងនៅ២០ថ្ងៃៗបកមកវិញ គេដកចូលមកបាត់ដំបងវិញ ។ អានឹងនិយាយជិតដល់កន្លែងចូលផ្លូវ ដកចូលបាត់ដំបងទៅជិតដល់មិនដឹងថាអាមេលើម៉េចទេ ។ ដល់ចូលដល់បាត់ដំបង រឿងខ្ញុំកើតមួយ កងនឹងត្រូវ២០នាក់នឹងត្រូវមកនៅក្រុងហើយណា ។ ប៉ុន្មានថ្ងៃមួយនឹងគេត្រូវដកពួកខ្ញុំចេញទៀត ដោយមូលហេតុមួយភ្លើងឆេះនៅរោងម៉ាស៊ីន០១ ឯដូនទាវនឹង ។ ឆេះម៉ាយប់ ស្អែកឡើងគេដកខ្ញុំចេញភ្លាម ។

ដានី : ម៉េចបានគេដក?

ម៉ាលី : មិនដឹងជាមូលហេតុអី អត់ដឹងរឿងទេ ។ អានឹងលែងជិះឡានទាហានហើយ ជិះឡានក្រុងយើងធម្មតា គេដាក់ទ័ពនឹងស្លៀកចេញមក គេហៅថាតំបន់អានឹងនេះចកធំ នឹងគេហៅកន្លែងកសាងគេ ។

ដានី : ចេញមកណា ចកធំនឹង?

ម៉ាលី : ដាក់ចកធំ ភ្នំតាផ្គួរ(ធិបតី) កន្លែងភ្នំតាផ្គួរ(ធិបតី)នឹង ដកកងទ័ពយកមកដាក់នឹង កងទ័ពគេចង់និយាយថាមានវិបត្តិអីគេដាក់នឹង ។

ដានី : ភ្នំធិបតីនៅកន្លែងណា?

ម៉ាលី : ខាងកើតបាត់ដំបងនឹង កោះចក ឃុំកោះ ភូមិចក ភ្នំតាផ្គួរនឹង ។

ដានី : ក្នុងស្រុកអី?

ម៉ាលី : នឹងស្រុកខេត្តបាត់ដំបង អានឹងគេហៅស្រុកឃុំ ស្រុកអីចេះ ប៉ុន្មានខេត្តៗបាត់ដំបង ។ នឹងចេញមកពីមោង(មោងឫស្សី)មក ទៅពីនេះទៅនៅប្រឡោះកណ្តាល ។ ភ្នំតាផ្គួរនឹង គេដាក់ស្រុកអី ស្រុកបាណន់ៗចក ។

ដានី : បាណន់ហួសពីភ្នំសំពៅមកខាងប៉ៃលិន?

ម៉ាលី : ទៅលិចទេ ។ ហឺ! ភ្នំតាផ្ដេរដឹងគេហៅដាក់ស្រុកអី ។

ដានី : នៅចន្លោះពោធិ៍សាត់នឹង អឺ! មោង(មោងឬស្សី) មក?

ម៉ាលី : អត់ទេមោង(មោងឬស្សី) ចេះមក បាត់ដំបងចេះមក នៅសល់ចន្លោះកណ្ដាលចេះមក ។ តែខ្ញុំនៅខាងកងចល័តនឹង គេនៅឲ្យដាន់ឥដ្ឋ ។

ដានី : គេឲ្យដាន់ឥដ្ឋ?

ម៉ាលី : វ៉ៃឥដ្ឋ ធ្វើឥដ្ឋក្បឿងលឿងៗ ពេញនឹង ទៅដល់ស្រុកមោង(មោងឬស្សី) ឃើញដល់កកោះ ឃើញ ដល់កកោះនឹងឃើញឃ្លាំងរោងឥដ្ឋក្បឿង ។

ដានី : ប៉ុន្ដែនៅកងទ័ពដដែល?

ម៉ាលី : កងទ័ពនៅគេដកម៉ាចំនួន នៅតែកងទ័ពនឹង២០នាក់នឹងនៅកងទ័ពនឹង គេប្រើដាន់ឥដ្ឋ ។ ហ្នឹងគេអត់ទាន់ដកថាអីគេ គេនៅប្រើចឹងថាឲ្យនៅដាន់ឥដ្ឋម៉ារយៈ ។

ដានី : រយៈពេលប៉ុន្មានទៅ?

ម៉ាលី : យី! ចប់ដល់គេដាក់គុកនោះ បានផុតដកខ្លួនបណ្ដោយ នៅនឹងយួរម៉ង ។ បាទ! ដាន់ឥដ្ឋនឹងហើយគេដកពីដាន់ឥដ្ឋ គេទៅឲ្យវែកទឹកបណ្ដោយ ធ្វើដាំដំណាំនៅជិតអាងនឹងម៉ង ។

ដានី : ជិតអាងណា?

ម៉ាលី : អាងចកតូច ចកធំនឹង មានអាងមួយធំទៀត ថាទៅនៅជាមួយចាស់ៗនឹងវែកហូរហែលចឹង ទៅបានខ្ញុំនិយាយដល់ថ្ងៃ១៧ និយាយជាមួយប្អូនឯងមិញនឹង ។ មានវ៉ាដ្យូមួយចាស់នឹង គាត់បើស្ដាប់នឹង គាត់ខ្លាចយួនវ៉ៃទៅលើកោះៗតាងអី ១២ខែ ខែធ្នូ ។

ដានី : ខែធ្នូ ឆ្នាំ៧៥?

ម៉ាលី : ហ្នឹងហើយ ប៉េកាំងផ្សាយ ខ្ញុំមិននិយាយតាមគេចឹង ។

ដានី : គេផ្សាយជាភាសាខ្មែរ?

ម៉ាលី : ហ្នឹងប៉េកាំងនិយាយខ្មែរ ។

ដានី : កាលនឹងគេផ្សាយយ៉ាងម៉េច?

ម៉ាលី : គេផ្សាយថា វៀតណាមវ៉ៃខ្មែរក្រហមធ្លាក់លើកោះតាង កោះអីចឹង ខ្ញុំក៏បើកស្ដាប់រឿងនឹង ។

ដានី : បើតាមអ៊ំនៅចាំ គេផ្សាយថាម៉េចខ្លះ?

ម៉ាលី : គេផ្សាយនិយាយពីរឿងវៀតណាមវ៉ៃលើកោះតាង ។

ដានី ៖ វៀតណាមវ៉ៃចូលលើកោះតាង?

ម៉ាលី ៖ ហ្នឹងហើយវ៉ៃយកកោះតាង ថាខ្មែរធ្លាក់ទឹកអីនឹងៗ ខ្ញុំក៏ឱ្យប្រាប់គ្នាឯង ស្អែកឡើងគេចាប់ដាក់គុក ខ្ញុំបំផុសបំផុលចលនាជាប់គុកៗ លែងមានរឿងអីទៀតហើយ ចប់ហើយ ។

ដានី ៖ គេចាប់អ៊ំដាក់គុកនៅណា?

ម៉ាលី ៖ នៅចកនឹង នៅវត្តចកនឹង ។

ដានី ៖ ពីអានឹងបើណាគេអ្នកចាប់?

ម៉ាលី ៖ អានឹងវា បើតាមចៅហ្វាយស្រុកកាលលើកមុននោះគេហៅអីគេ តាខុនៗម៉េចទេ តាខុននឹងនិយាយមិនសូវច្បាស់ ។ អានឹងក្នុងនឹងមិនទាន់ដល់ ចឹងមិនដឹងអាណាមេធំ ឃើញតែមួយទៅមួយបាត់ ទៅអាមួយវ៉ៃតគ្នាមិនដឹងអាណាធំ ។

ដានី ៖ គេចាប់អ៊ំដាក់គុកនឹងក្នុងខែ១២ ៧៥នឹង?

ម៉ាលី ៖ មិនទេអា៧៥នឹង យើងមកពីនោះរហូតមកដល់ហើយ មកដល់៧៧នេះហើយនឹងនិយាយ ដល់យើងកសាង៧៧នេះហើយនឹង ។ ៧៧នឹងមកយើងរស់នៅកាលពីដកចេញពីនោះ មក ។ ៧៥យើងមិនចប់ យើងចូលពេញបាត់ដំបងហើយនឹងខ្ញុំនិយាយអាមិញនឹងដូរ ដំណាលៗហើយ៧៥ហើយណា ។ អានឹងយើងរៀបអា១៨នេះអានឹងមុនហើយចប់៧៥ គេរៀបចល័តពេលតែនឹងហើយ ។ ចឹងបានខ្ញុំនិយាយមិញកំពុងអាក្រោយ៧៥ ៧៦ ៧៧នេះ ។

ដានី ៖ បាទ! ប៉ុនអ៊ំមានប្រសាសន៍មិញថា ពេលអ៊ំទៅជាន់ឥដ្ឋជាន់អីនោះ?

ម៉ាលី ៖ ហ្នឹងៗ ។

ដានី ៖ អានឹងឆ្នាំ៧០ប៉ុន្មាន?

ម៉ាលី ៖ អានឹងវា៧០ចូល៧៧ហើយ នឹងមកដល់នឹង ។

ដានី ៖ ចូល៧៧?

ម៉ាលី ៖ បាទ! បើ៧៥យើងឡើងពីប៉ៃលិន បកចុះបកឡើងមកដល់កកោះ គេបញ្ជូនមកកកោះ គេហៅកកោះអន្តការណាក៏គេដឹងដែរ ។ កន្លែងកសាង ។

ដានី ៖ ក៏ប៉ុន្តែអ៊ំស្តាប់វិទ្យុនឹងក្នុងឆ្នាំ៧៧នឹង?

ម៉ាលី ៖ ហ្នឹងហើយឆ្នាំ៧៧នឹងឯង ។

ដានី ៖ ឆ្នាំ៧៧ វិទ្យុ?

ម៉ាលី ៖ បាទ! វិទ្យុចាក់ផ្សាយដែលថាប៉េកាំងវ៉ៃខ្មែរធ្លាក់ពីលើកោះតាង ។

ដានី ៖ ប៉េកាំង ហើយវៀតណាមក?

ម៉ាលី ៖ អឺ!នែក ប៉េកាំង គេថាវៀតណាមវ៉ៃ ។ ខ្ញុំស្តាប់បានប៉ុននឹង មិនស្តាប់បានច្រើនណា ។

ដានី ៖ ដល់ពេលស្តាប់ទៅ ពីណាគេចោទ?

ម៉ាលី ៖ ទេ! រកមុខចោទអត់ឃើញ គេចាប់អស់បានដឹងថាយើងមានទោសប៉ុនណានោះ ។

ដានី ៖ ពីណាអ្នកចាប់?

ម៉ាលី ៖ អើ!ខាងនឹង ប្រធានសហករណ៍គេនឹង ។ ប៉ុនប្រធានសហករណ៍នឹងអាចាប់ខ្ញុំទៅនឹងអាចាប់ខ្ញុំទៅនឹងក៏គេវ៉ៃចោលតគ្នាអស់ហើយមិនដឹងអាណាមួយធំអត់នៅ ដឹងគេហៅតាប៉ែលៗ ដល់ពេលខ្ញុំចេញផុតទៅ គេថាតាប៉ែលគេវ៉ៃងាប់ដូចគ្នា តគ្នា ។

ដានី ៖ ដល់ពេលគេចាប់អ៊ីយកទៅគេយកអ៊ំទៅណា?

ម៉ាលី ៖ យកៗមកដាក់គោកកាច់រទេះ ។

ដានី ៖ កាច់រទេះនៅណា?

ម៉ាលី ៖ ក្នុងវត្តៗកាច់រទេះ ។

ដានី ៖ វត្តកាច់រទេះនៅណា?

ម៉ាលី ៖ នឹងអ្នកមានទោសដាក់នឹង ជិតភ្នំធិបតីនឹងដែរ ។

ដានី ៖ ជិតភ្នំធិបតី?

ម៉ាលី ៖ ហ្នឹងហើយ ។

ដានី ៖ ដាក់នៅនឹងរយៈពេលប៉ុន្មាន?

ម៉ាលី ៖ យី ដាក់ទាល់តែយូរ ដាក់ទាល់ដល់រថក្រោះវៀតណាមទៅពីនេះ នឹងបានរត់រួច ។ នឹងកុំបានវៀតណាមដាក់រថក្រោះ ហើយមានស្លឹកដូងមកពីនឹងទៅៗបាត់ដំបង ។ ថ្ងៃសារដំបូងអត់ដឹងថាខាងណាៗ ។

ដានី ៖ ចុះអ៊ំកាលជំនាន់នឹងអ៊ំដែលបានជួបតាម៉ុកទេ?

ម៉ាលី ៖ អត់ជួបទេ អត់បានជួបទេ លែងជួបហើយ ។

ដានី ៖ ចុះអ៊ំជាប់សាច់ញាតិគាត់ដែរ?

ម៉ាលី ៖ អត់ជួប ។

ដានី ៖ ត្រូវជាជីដូនមួយគាត់ដែរ?

ម៉ាលី ៖ អត់ដែលបានជួបប៉ះគ្នា ។

ដានី ៖ អត់ដែលប៉ះគ្នា?

ម៉ាលី : បាទ! អត់ៗ ។

ដានី : គាត់អត់ដែលបានមកជួប?

ម៉ាលី : គាត់ដែលជួប ហើយយើងមិនដែលទៅ ខ្ញុំក៏មិនដែលកាត់ជួប សូម្បីតែនៅជំរំគេទៅលាន់ខ្ញុំអត់ទៅ ។

ដានី : ម៉េចចឹង?

ម៉ាលី : មិនទៅ ។

ដានី : ហេតុអី?

ម៉ាលី : ចឹងបានចង់និយាយថា គេធ្វើធំៗអីណា ប៉ុនគ្រាន់ថា ខ្ញុំមិនចូលចិត្តដាក់គុក ឈប់ ។ មិនតស៊ូជាមួយ ។

ដានី : មិនចូលចិត្តតស៊ូជាមួយ?

ម៉ាលី : បាទ! មិនតស៊ូណា អត់ដឹងខុសត្រូវផងនឹង ប្រជាជនស៊ីបបរស៊ីអីមានដឹងណា ខ្ញុំអត់ពេញចិត្តទៅរក បើម៉ែខ្ញុំហៅៗទៅៗខ្ញុំទៅ ។ ខ្ញុំទើបនឹងជួបរត់យួនមកនេះមួយភ្លែត ជួបគ្នាបានម៉ាត់ គាត់ទៅទៀតហើយ ។

ដានី : ជួបគាត់ថាម៉េច?

ម៉ាលី : គាត់ពិការហើយ គាត់មកជួបមានថាម៉េចមកបញ្ញាឲ្យឯងតស៊ូវ៉ៃ ឯងថាទៅវ៉ៃអាណាបើចូលពេញដីហើយ ។

ដានី : គាត់មកបញ្ញា គាត់អត់មានសួរសុខទុក្ខអុំ?

ម៉ាលី : អត់ ហ៊ើ!សួរសុខទុក្ខស្អីបើមកដល់ប្រជុំភ្លាមវ៉ៃដាក់លិចកើត អាណាទៅវ៉ៃដាក់លិចកើត ។

ដានី : ប៉ុនគាត់ដឹង អុំត្រូវបងប្អូនជីដូនមួយ?

ម៉ាលី : ដឹង ស្គាល់ ។

ដានី : គាត់ស្គាល់ ប៉ុន្តែគាត់អត់មានសួរសុខទុក្ខអី?

ម៉ាលី : អត់ៗសួរទេ កំពុងប្រគាយប្រគប់ ។

ដានី : ប៉ុនកាលពាយ័ព្យ នឹងការគេចាប់ឆ្នាំ៧៧ដូចខាងនិរតី ខាងតាម៉ុកគាត់ចូលមកតើ?

ម៉ាលី : ចូលមកៗខ្ញុំដាក់បណ្ដើរ ខ្ញុំដាក់ទ័ពបណ្ដើរៗរហូតដល់១០២ ។

ដានី : ប៉ុន្តែ គាត់ចូលមកចឹងអត់ដែលចូលមកដែរ?

ម៉ាលី : អត់ជួប ។

ដានី : អត់ដែលជួប?

ម៉ាលី ៖ អត់ដែលជួប គេឮថាតាម៉ុកបះបោរនឹង ខ្ញុំដោះផុតវាលនៅវាលស្រែ ។

ដានី ៖ ចឹងអ៊ំជាប់នៅនឹងរហូតដល់?

ម៉ាលី ៖ រហូតដល់រំដោះវៀតណាម ។ ហ្នឹងហើយគ្រាន់ចេញសារដំបូង វាមិនមែនគេលែងទេ គុកនឹងវៀងផ្ញើលខ្លួនវាបែកតែម្តង ទាំងគេទាំងខ្ញុំម៉ង ។ ហើយដល់ក្រោយមកម៉ាសារទៀត បានផ្ទះអាវុធម៉ង ។ ចឹងបានខ្ញុំចេញពីនឹងបានឆ្ងាយជួបប្រពន្ធ ជួបកូនម៉ង ។

ដានី ៖ ចឹងក្នុងសម័យពី៧៥ដល់៧៩ អ៊ំអត់ដែលបានជួបប្រពន្ធកូន?

ម៉ាលី ៖ អត់ទេ មើកជួប៧៧ ។

ដានី ៖ ជួបនៅណា ៧៧?

ម៉ាលី ៖ ជួបនៅបាត់ដំបង កាលណាគេជូនឡានអាគ-១៨យើងទៅ គេជូនគ្រួសារយោធាចូលបាត់ ដំបង ។

ដានី ៖ ចូលទៅបានជួបគាត់?

ម៉ាលី ៖ អឺ! ជួបបានម៉ាភ្លែតៗទៅ យើងទៅទៀតទៅ ។

ដានី ៖ ចុះប្រពន្ធកូនអ៊ំ ឪពុកម្តាយទៅនៅណាទៅ?

ម៉ាលី ៖ ពុកនៅពោធិ៍សាត់នោះ គេយកតែប្រពន្ធគ្រួសារទ័ពនឹងយកមកតាមចឹងទៅ ។

ដានី ៖ ចុះពេលដែលគេបញ្ជូនអ៊ំមកកន្លែងភ្នំធិបតីនឹង ប្រពន្ធមកជាមួយអត់?

ម៉ាលី ៖ នឹងគេបញ្ជូនមកៗជាមួយ ។

ដានី ៖ មកនៅជាមួយគ្នា?

ម៉ាលី ៖ បាទ! មកជាមួយគ្នា ។

ដានី ៖ ចុះពេលនឹងយ៉ាងម៉េចទៅ?

ម៉ាលី ៖ ពេលគេបញ្ជូនប្តីយកដាក់គុកទេ ប្រពន្ធនៅវែក សែងលីនឹងគេទៅ ។

ដានី ៖ ប្រពន្ធនៅលើកដី?

ម៉ាលី ៖ អឺ!នៅធ្វើនឹង នៅលើកដីលើកអី អាកូនតូចនឹង ។

ដានី ៖ កូនប៉ុន្មាន?

ម៉ាលី ៖ អានឹងបានកូន ហ្នឹងកំណើតមីធំហើយ ដល់អាប្រុសអា៧៧នឹងមួយ បានកំណើតនឹង មួយ ។

ដានី ៖ ចឹងនៅជាប់គុកនឹង អ៊ំជាប់យូរ?

ម៉ាលី ៖ ជាប់យូរ ជាប់ដូចខ្ញុំថាទាល់តែវៀតណាមមានអាវរំដោះមក ។

ដានី ៖ បាទ! ជាប់នឹងគេមានធ្វើទារុណកម្ម គេមានឲ្យហូបចុកគ្រប់គ្រាន់?

ម៉ាលី ៖ ហ៎! កុំនិយាយអារឿងហូបចុកចេះថាខ្ញុំប៉ុននេះ ខ្ញុំដឹងថាសុទ្ធតែក្មេងវាវ៉ៃខ្ញុំសួរចម្លើយ ព្រោះខ្ញុំនៅក្នុងគុកស្តាប់សួរ សួរអ្នកនេះត្រូវទោសអី ។ ចុះយើងជាអ្នកចេះដឹងដឹកនាំមួយដែរ តែចង់ដឹងសួរអាអ្នកដែលជាប់ដូចគ្នានឹង សួរត្រង់នេះ មួយបាក់កណ្ដៀវចឹងទៅក៏មានទោសជាប់ដែរ ។ មួយនោះមានបាយក្ដាំងស៊ីអង្ករ ការដ្ឋានចែកបាយមក មានក្ដាំងចឹងគាត់ហាលទុក ដើម្បីទៅភ្ជួរទៅដាក់ហោប៉ៅអាវ គេថាឯងលាក់ស្អីណា គេដាក់គុកចឹងមកហូរហែលចឹងមក ។ ហើយសុទ្ធតែវ៉ៃសួរចម្លើយ ហើយខ្ញុំមួយគ្រាន់ថានិយាយជាមួយអ្នកត្រួតត្រាក្មេងៗនឹង លួងៗវាចឹងទៅ ។ «ប្អូនឯងចង់ដឹងមិនបាច់ទេ មើលតែឯកសារម៉េចខ្ញុំមកចឹងហើយ អត់ចាំបាច់ប្រកែកថាមានទោស មិនមានទោសទេ» ។ ហើយនិយាយតាម គេចឹង ស្រួលដែល ថា«ឥឡូវថាអត់ប្រកែកទេ បើអង្គការគាត់ខាងលើដាក់ថាមានទោសៗ ហើយ អត់បាច់និយាយច្រើនអាអស់នឹងនិយាយចឹងស្ដាប់គ្នា អត់វ៉ៃទេ» តែបាយគ្រាន់ ថាយូរទៅកាន់ស៊ិតទៅ ។ ប៉ុន្មានខែ មើលខ្ញុំ៧០គីឡូ ចេញរួចមកថ្លឹងបាន៦៥គីឡូនឹងនៅ ខ្លាំងហើយនៅតែស្បែកហើយនិងឆ្អឹង ។ ចឹងបានគេចេញមកគេថាយីអស់សាច់រលីងហើយនៅ៦៥គីឡូដែរ អានឹងឆ្អឹង ។

ដានី ៖ ប៉ុន្តែគេឲ្យធ្វើការងារអីដែរអត់អ្នកទោស?

ម៉ាលី ៖ យប់ចឹងគេដាក់ខ្នោះយើងចឹង ថ្ងៃគេចេញមកជួយដកស្ទូង គេបណ្ដើររួ ទៅដកប៉ុកប៉ាក់ៗមកវិញទាំងសើមកេចកាកនឹង ។ ហើយបើអ្នកដែលរៀងទ្រង់ល្មើយដល់-កវា វាងាប់នៅក្នុងនឹងក៏មាន ល្មើយដល់-កវាលែងដោះលែងអីស្អីៗអស់ ។

ដានី ៖ តែនឹងបានជួបប្រពន្ធកូនពេលជាប់ទោស?

ម៉ាលី ៖ អត់ទេ អត់មានប្រពន្ធកូនណាទៅអើតជិតយើងបានទេ?

ដានី ៖ តាមមើលអ៊ំខុសស្អីធ្ងន់ គ្រាន់ស្ដាប់វិទ្យុនឹងខុសដែរ?

ម៉ាលី ៖ អត់ ភាសានយោបាយ ។

ដានី ៖ ភាសានយោបាយ?

ម៉ាលី ៖ ហ្នឹងគេដាក់នៅក្នុងនឹង ខ្ញុំឃើញគេអានមើលនឹង ។

ដានី ៖ បាទ! ភាសានយោបាយ?

ម៉ាលី ៖ នយោបាយ ។

ដានី ៖ គ្រាន់តែស្ដាប់វិទ្យុក៏គេចាប់ដាក់គុក អត់មានរឿងអីផ្សេងទៀតទេ?

ម៉ាលី ៖ អត់ទេ គ្មានរឿងទេ ។ ចុះដូចខ្ញុំសង្កេតក្នុងនឹង គ្រាន់បាក់កណ្ដៀវខ្នាំងដែរនឹង ។ ខ្ញុំដើរសង្កេតសួរអ្នកទោសទាំងអស់នឹង ។

ដានី ៖ ចុះអ្នកទោសនឹង អ៊ំដែលឃើញគេយកទៅសម្លាប់មានអីដែរ?

ម៉ាលី ៖ ទេ! បើនៅកន្លែងនឹងអត់ឃើញយកទៅសម្លាប់ ព្រោះយើងអត់ឃើញដែរ ឃើញងាប់នៅ ក្នុងឃ្នោះដែកនឹងមាន ។

ដានី ៖ មានងាប់?

ម៉ាលី ៖ មានងាប់ ។

ដានី ៖ ប៉ុន្ដែមានបាត់ដូចថាជាប់ច្រើន មានគេយកទៅបាត់?

ម៉ាលី ៖ អត់ឃើញបាត់ទេ ក៏ប៉ុន្ដែវាបាត់ក្នុងលក្ខណៈមួយ ចង់និយាយថា គេអត់ប្រាប់យើងនៅក្នុងនឹងដូចគ្នាទេ ។ បើទៅជាប់យើង ហើយបាត់នឹង គេថាអ្នកនឹងរួចទោសលែង អត់ដឹងៗ ទាំងអស់ ។

ដានី ៖ តាមមើលលែងមែន ឬក៏គេយកទៅសម្លាប់?

ម៉ាលី ៖ យើងស្មានមិនត្រូវ បើនៅក្នុងនឹងយើងលែងគិតពិចារណារឿងអីហើយ វាដេកទៅស្ពុងស្ពុកគ្មានរឿងអីវាស្ដើងអស់ហើយ ចឹងបានថា ។

ដានី ៖ ប៉ុន្ដែជិតទាន់នឹង អ៊ំដឹងថាតាម៉ុកគាត់ធ្វើធំដែរអត់ ដឹងដែរអត់?

ម៉ាលី ៖ តាម៉ុក ដឹងតើ ដឹងថាធ្វើភូមិភាគ ប៉ុនអត់ដឹងថាគាត់នៅណា ។

ដានី ៖ កាលពីសម័យអ៊ំធ្វើការនឹង អ៊ំជាប់គុកនឹង អ៊ំដឹងថាតាម៉ុកគាត់នៅភូមិភាគ?

ម៉ាលី ៖ ដឹងៗ ។

ដានី ៖ ដឹងថានៅនិរតីអីចឹងដែរ?

ម៉ាលី ៖ និរតីដែរ ។

ដានី ៖ ចឹងអ៊ំអត់អាចឲ្យគាត់ជួយអីបានទេ?

ម៉ាលី ៖ អត់ៗមានការទាក់ទងគ្នា ។

ដានី ៖ អ៊ំអត់មានបានផ្ដាំផ្ញើធ្វើម៉េចឥឡូវត្រូវជាសាច់ញាតិរបស់គាត់ ត្រូវជាជីដូនមួយ ថាឥឡូវជាប់គុក ហើយត្រូវបងត្រូវជួយប្អូនអីនេះអត់មានទាក់ទងចឹង?

ម៉ាលី ៖ អារឿងនឹងមួយ ប៉ុនខ្ញុំយល់ចេះ និយាយទៅបើកាលណាខ្ញុំបង្ហើបខ្សែតាម៉ុកងាប់ផុយណាស់ ព្រោះដឹងថាខ្សែធំខ្សែអី វាខុសតិចតួចវាដាក់បាក់ទៅមានរឿងអី អានឹងខ្ញុំយល់ថា

អានឹងមួយខ្ញុំអត់និយាយទេ ។ ទោះបីយ៉ាងម៉េចក៏ដោយ អត់មានគិតគូពីរឿងខ្មែរធំខ្មែរតូច អី ។

ដានី : ក្រែងលរគេយោគយល់អីថាយើងខ្មែរធំអី?

ម៉ាលី : អត់យោគយល់អី ខ្ញុំដឹងថាអត់ម៉ង ។

ដានី : អត់ទេចឹង?

ម៉ាលី : អត់ម៉ង ។

ដានី : គេប្រឆាំងខ្មែរគ្នាម៉េច?

ម៉ាលី : ទេ! យើងត្រូវប្រឆាំង កាលពីម៉ាហឹងខ្ញុំនៅភូមិពាយ័ព្យដូចគ្នាទាំងអស់ ស្មើគ្នាទាំងអស់អត់ទាន់មានអីទេ ។ គេគ្រាន់ថាគិតបញ្ចូលកម្មាភិបាលមកពីនិរតីចូលម៉ាឆុចនិរតី ពាយ័ព្យក្បត់ទាំងអស់ ។ វ៉ៃម៉ាសារនឹង រលីងក្បត់ ។

ដានី : ពួកនិរតីវ៉ៃ?

ម៉ាលី : ហ្នឹងហើយ ពួកនិរតីមកបង្ក្រាបពួកពាយ័ព្យ បាត់ម៉ាសារអាណាកម្មាភិបាលណាមិនដឹងទៅណាណៃទេ សូម្បីតែមេទ័ពអីណាណៃក៏ផ្លាស់ប្តូរ ។

ដានី : តាខ្វែងតាអីក៏បាត់អស់?

ម៉ាលី : ហ្នឹងហើយ ទៅតាមហូរហែល ។ ហើយដល់មជ្ឈឹមទៀតនិរតីដែរ អាមជ្ឈឹមធំគេណានោះមកតនិរតីចាស់នឹងម៉ារាលទៀត ។ ចឹងបានថាមិនដឹងរកអាណាធំអត់ឃើញ ។

ដានី : ម៉េចទៅចឹង ខ្ញុំអត់ដឹង?

ម៉ាលី : អួយ! ខ្ញុំវាវង្វេងស៊ុង ។

ដានី : អ៊ំអត់ដឹងរឿងដែរ?

ម៉ាលី : អត់ដឹងរឿង ដល់វាដាន់គ្នាចឹង ដល់អាមជ្ឈឹមវាសំឡុតនិរតី គេថាស្អីៗបូព៌ាក្បត់អីណាណៃមកសំឡុតគ្នាម៉ាដាន់នឹងអីណាទៀត ខ្ញុំលែងយល់ហើយ ។

ដានី : ចុះកាលពីមុនអ៊ំផ្លាស់មកនៅភ្នំធិបតីកាលអ៊ំនៅគ-១៨កងទ័ពអីនឹង អ៊ំមានតួនាទីអី យើងមានឋានៈអី?

ម៉ាលី : នៅក្រុម នៅមេក្រុមគេនៅឡើយ ។

ដានី : មេក្រុម?

ម៉ាលី : មេក្រុមនឹងធ្វើស្រែកសិកម្មទ័ព ។

ដានី ៖ អាចថាយើងមានឋានៈយើងអាចជួបដូចជា កម្មាភិបាលធំៗដូចតាខ្លែន តាដូចតាអីតា ផ្សេងៗ តាកឺ តាញឹមអី យើងអាចទាក់ទងជួប្រាស្រ័យធ្វើការងារជាមួយគាត់ដែរ?

ម៉ាលី ៖ អើយ! ទេ!ខ្ញុំអត់ដែលទៅជួបទេ ប៉ុនការងារខ្ញុំឃើញ គាត់ចុះមកជួបប្រាប់ចេះចុះ គាត់ជួប តែហៅទៅជួបអត់ទេ។

ដានី ៖ បាទ! គាត់ចុះមកប្រាប់?

ម៉ាលី ៖ បាទ!

ដានី ៖ កាលអ៊ំនៅក-១៨៧នឹង?

ម៉ាលី ៖ បាទ!

ដានី ៖ ១៨នឹងរបស់នឹងចំនុះឲ្យ របស់ភូមិភាគម៊ង?

ម៉ាលី ៖ របស់ភូមិភាគម៊ង ក្រុមពាយ័ព្យនឹង។

ដានី ៖ ក្រុមពាយ័ព្យ?

ម៉ាលី ៖ បាទ! ភូមិភាគពាយ័ព្យ។

ដានី ៖ យើងនៅមើលប្រជាជនៗ គាត់ធ្វើអីកាលនឹង?

ម៉ាលី ៖ ហ៊ោ! កាលនឹងនៅជាកង ប៉ុនគេបំបែកទ័ពអាខ្លះម៉ាកងទៅនេះ ម៉ាកងទៅនោះ។

ដានី ៖ ប៉ុនអ៊ំថាមកកំពីងពួយ?

ម៉ាលី ៖ បាទ! កងនឹង ក៏គេដាក់ខ្ញុំម៉ាក្រុមមើលប្រជាពលរដ្ឋជីកស្រះជីកអីចឹងណ៊ា។

ដានី ៖ ជីកអាង?

ម៉ាលី ៖ ជីកអាងនឹង។ ដឹងមើលរឿងអី បើឃើញប្រជាជនវែកគគ្រឹកគគើលចឹង។

ដានី ៖ យើងមើលធ្វើម៉េច យើងអង្គុយ?

ម៉ាលី ៖ ចឹង ហ៊ោ!យើងដើរ... ដឹងដើរអីចេះនាំគ្នាដើរចឹងទៅ។

ដានី ៖ ក្រែងលរគេឲ្យយើងដើរមើល ក្រែងលរមានប្រជាជនណាអត់ធ្វើការ?

ម៉ាលី ៖ អត់ទេ គេចង់និយាយថាមានខ្មាំង។

ដានី ៖ មានខ្មាំង?

ម៉ាលី ៖ ចឹងបានគេប្រាប់ថាមានខ្មាំងបង្កប់ អីចេះៗ។ ហើយពួកខ្ញុំមិនដឹងខ្មាំងណា មិនដឹងខ្មាំងនៅណា។

ដានី ៖ មានខ្មាំងមែនអត់?

ម៉ាលី ៖ បាទ! ដឹងខ្មាំងនៅណា បើគ្រាន់អ្នកឯងជីវាយ កាប់ចឹង។

ដានី ៖ មានចាប់បានដែរអត់? គេមានប្រាប់ថាអូ! អ្នកនេះខ្លាំង យើងត្រូវទៅ?

ម៉ាលី ៖ អត់ យើងសិទ្ធិធំជាងគេម៊ង ។

ដានី ៖ បាទ?

ម៉ាលី ៖ យើងសិទ្ធិអា២០នាក់កងភូមិភាគធំ ត្រួតត្រាដើរមើលត្រូវការចាប់ចងអីយើងធ្វើម៊ង ។ ប៉ុនដល់ពួកខ្ញុំទៅមិនដឹងមើលឃើញអី ឃើញតែវែកចឹង ថ្ងៃឡើងទៅបាញឈូសស៊ុ វៃបាន២០ថ្ងៃដកមកវិញ គេដកប្រញាប់មកវិញ ។

ដានី ៖ ដែលយើងធ្វើអត់បានផលប្រយោជន៍?

ម៉ាលី ៖ ហ៊! មិនដឹងយ៉ាងម៉េច គេឲ្យទៅប៉ុននឹង២០ថ្ងៃ គេហៅមកវិញ ហៅយកមកដាក់កកោះនឹងម៊ង ។ ចឹងសកម្មភាពទៅនឹង មិនដឹងយ៉ាងម៉េច ជិតាស់គេយ៉ាងម៉េច ។

ដានី ៖ ២០កងរបស់អ៊ីនឹងគ្រប់គ្រងមជ្ឈិម ក្រុមដែលធំជាងគេថាយកទៅពិនិត្យមើលទៅគណៈកងគណៈតំបន់?

ម៉ាលី ៖ ទាំងអស់ ។

ដានី ៖ ទាំងអស់នឹងយើងទៅមើលគេ តែអ៊ំទៅ២០ថ្ងៃនឹង មើលអត់ឃើញអី ក៏គេដកមកវិញ?

ម៉ាលី ៖ គេដកមកវិញម៊ង ។

ដានី ៖ ប៉ុន្តែគេប្រាប់ដែរ មុនទៅមើលគេប្រាប់ថាមាន?

ម៉ាលី ៖ មានខ្មាំងបង្កប់ ដើរធ្វើខ្មាំងបង្កប់អីបំផុសប្រជាជនអីនឹងណា ។

ដានី ៖ ចុះយើងមើលម៉េចឃើញ បើគេអត់ប្រាប់ថាមួយណាខ្មាំង យើងទៅឃើញតែគេធ្វើការអី?

ម៉ាលី ៖ ហ៊! អានឹងទាល់តែច្បាប់ៗគេមាន ។

ដានី ៖ មាន?

ម៉ាលី ៖ គេឲ្យយើងដាក់គំនិតអង្គុយ....(ស្តាប់មិនបាន) ចេះចុះ ប៉ុនយើងដាក់ដូចគេថាបញ្ឆោថាចឹងម៉ាបង្គោលភ្លើងដាក់មួយដាក់២ហែលតាមយប់ចឹងទៅ ។ ប៉ុន្តែប្រជាជនវែកៗគាត់វែកចឹងជួនកាលបងប្អូនខ្លះគាត់វែកជាមួយប្រជាជននឹង ដូចគ្នាចឹងនៅក្នុងកងយើងនឹង ឲ្យវាយាមនៅឈរនឹង បង្គោលភ្លើង២នាក់អ្នកវែក២នាក់នឹង អ្នកទៅវែកលេងជាមួយគេនឹង ។

ដានី ៖ យើងទៅវែក ក្នុងនាមថាយើងទៅ?

ម៉ាលី ៖ ហ៊! អ្នកទៅវែកៗធម្មតា អត់មានគិតពីរឿងអីផងនឹង ។

ដានី ៖ អត់គិតថាយើងទៅតាមដាន?

ម៉ាលី ៖ តាមដានណា ដាក់វែក កងចល័តហើយកងចល័តល្មមៗខ្លាចមិនឲ្យវែក តែស្គាល់គ្នាមិនឲ្យវែកមួយ ថាយើង...(ស្ដាប់មិនបាន) ចេះៗ ។

ដានី ៖ ចឹង២០ថ្ងៃនឹង ទៅអត់មានបានចាប់អី?

ម៉ាលី ៖ អត់ ចាប់ស្អី មានចាប់អី អត់ឃើញអីផង ។

ដានី ៖ កាលនឹងអ្នកដែលប្រាប់ឲ្យទៅតាមដានតាញឹម តាអីនឹង?

ម៉ាលី ៖ តាញឹម អឺ!តាខ្វែង ។ ប៉ុនកាលនឹងវាមាននេះមួយ មិនចំតាខ្វែងទេ បន្ទាប់តាខ្វែងគេហៅកងវរៈទី១ឈ្មោះ កន ដែរ ប៉ុនក្មេង តែឥឡូវងាប់បាត់ហើយ កននឹង ។

ដានី ៖ កននឹងអ្នកប្រាប់?

ម៉ាលី ៖ កននឹង អ្នកកងវរៈផ្ទាល់ចេញពីខ្វែងមក ។

ដានី ៖ អ្នកប្រាប់ មិនមែនតាញឹម តាកឺ?

ម៉ាលី ៖ មិនមែនទេ អត់ ហ្នឹងមជ្ឈឹមគេហើយ ។

ដានី ៖ ចឹងអ្នកនេះច្រើនតែយោធាទេ អ្នកដែលចាត់ចែងទៅចាប់?

ម៉ាលី ៖ នឹងហើយ យោធា គេប្រើឲ្យទៅ ។ ហើយយោធានឹងមិនខ្លាំងដល់នេះទៀត ពួកនេះចាប់ឈ្លុយទៀត គេហៅកងឈ្លបៗភូមិ ឈ្លបឃុំគេនឹងអានឹងបានពិសេសស្មើនឹងគណៈសហករណ៍គេ អានឹងបានខ្លាំងគេ ។

ដានី ៖ អានឹងអត់ចាំបាច់ពិភាក្សាអីគេទេ?

ម៉ាលី ៖ អត់ទេ អានឹងតាមប្រធានសហករណ៍គេបញ្ជាទៅហើយ អានឹងវាតាមប្រធានបទ បើយើង អត់ឃើញទេ ឮប្រជាពលរដ្ឋនិយាយ ។ ចឹងបានកងទ័ពចុះទៅតាមភូមិគាត់និយាយអស់ ហើយ សំនេះសំណាលរឿងសុខទុក្ខបាយស៊ីស្លាប់រស់ ។ ពុកខ្ញុំមិនហូបបាយដោយមូល ហេតុអី ។

ដានី ៖ ចឹងគាត់អត់ហូបបាយ ដោយសារមូលហេតុថា ពួកគាត់ដឹងថាចាប់អ៊ឹចាប់អី ឬក៏គាត់អន់ចិត្ត តូចចិត្តរឿងអី សតិអារម្មណ៍រឿងអី?

ម៉ាលី ៖ អត់ទាន់ចាប់ទេកាលនឹង អត់ទាន់មានចាប់ខ្ញុំទេ គាត់នៅ អន់ចិត្តនឹងសង្គមនឹងម៉ង បានគាត់មិនហូបបាយ ។

ដានី ៖ គាត់អត់ចិត្ត?

ម៉ាលី ៖ បាទ!

ដានី ៖ ចុះម៉េចបានគាត់អត់ទៅនៅខាងនិរតី ទៅនៅជាមួយតាម៉ុកអីវិញ ពីព្រោះកាលនឹងដូចថា យើងមានសាច់ញាតិធ្វើធំចឹង ក្រែងលរយើងអាចថាយើងបានស្រួល?

ម៉ាលី ៖ អត់ៗ

ដានី ៖ គាត់អត់ចង់ទៅខាងតាកែវខាងអី?

ម៉ាលី ៖ អត់ទៅ គាត់នៅតែដីស្រែគាត់ កំសត់នឹងម៉ង់ៗ មើល៧០រដ្ឋប្រហារហើយនឹង គាត់នៅស្រូវគាត់៣-៤ជង្រុកនឹង បានចាប់ដីបានធ្វើស្រែៗ

ដានី ៖ ចឹងឪពុកម្ដាយអ៊ំ កាលជំនាន់នឹងគាត់អត់ដែលបានជួបតាម៉ុក អត់ដែលបានជួបទាក់ទងអីជាមួយតាម៉ុក?

ម៉ាលី ៖ អត់ៗដែលទាក់ទង ព្រោះតាម៉ុកគាត់ចាប់រដ្ឋប្រហារ គាត់ទៅតាកែវ បងប្អូនតាកែវនឹងយើងនៅពោធិ៍សាត់ម៉ាគ្រួសារៗ

ដានី ៖ ចុះយាយគួប?

ម៉ាលី ៖ យាយគួបនឹងក៏នៅនេះៗ តែដល់ពេលណាទេ បានគាត់ទៅជួប គាត់បែកពីខ្ញុំបាត់ គាត់ចេញពីពោធិ៍សាត់នេះបាត់ៗ

ដានី ៖ ចេញពីពោធិ៍សាត់?

ម៉ាលី ៖ ចេញពីពោធិ៍សាត់នេះបាត់ៗ

ដានី ៖ អូចឹង?

ម៉ាលី ៖ ហ្នឹងហើយទៅជួបបងប្អូនគាត់ណាៗៗ

ដានី ៖ ប្ដីគាត់ឈ្មោះអី យាយគួប?

ម៉ាលី ៖ បងចិនៗ

ដានី ៖ ស្លាប់ពីអង្កាល់?

ម៉ាលី ៖ ស្លាប់កាលនឹងរំដោះ យើងរំដោះហើយ គាត់ជិះរទេះភ្លើងទៅមករកប្រពន្ធគាត់ៗបែកទៅតាមតាម៉ុកបាត់ទៅ គាត់នៅក្នុងនេះ ជិះរទេះភ្លើងស្លាប់ ក្រឡាប់កាលនឹងក្រឡាប់រទេះភ្លើង ណាទេ ដូចកំពង់ឆ្នាំងទៀតចេះមិនដឹងៗ

ដានី ៖ មុនឆ្នាំ៧៥ទៀត មុនបែក មុនរំដោះ?

ម៉ាលី ៖ អត់ទេ យើងមុននឹងវៀតណាមចូលនេះៗ

ដានី ៖ មុនវៀតណាមចូល?

ម៉ាលី ៖ អឺ! មុនវៀតណាមចូលហើយយើងមិនចាប់បានជិះរទេះភ្លើងទៅមក ។ អានឹងប្រពន្ធមិននៅ ដងវែក ចឹងអាខ្វះនៅជិតស្រះកែវអីចឹង ហើយប្ដីនៅក្នុងចេះទៅ ចេះជិះដើរទៅមកពីអូរ ជ្រៅ, ប៉ោយប៉ែត, អត់ទាន់ដឹងទេ ។

ដានី ៖ គាត់ធ្វើអីដែរ?

ម៉ាលី ៖ គាត់អត់ធ្វើអីទេ គាត់ដើររកប្រពន្ធគាត់ ។

ដានី ៖ កាលពីសម័យពន្ឋាំ គាត់ធ្វើអីដែរ?

ម៉ាលី ៖ កាលពីសម័យពន្ឋាំ តស៊ូ គាត់គណៈតំបន់ដែរនឹង គណៈស្រុកមួយដែរនឹង ។

ដានី ៖ គណៈស្រុក?

ម៉ាលី ៖ ប៉ុនគាត់ខុសអី គេដកគាត់តាំងពីនឹងមក ចិន ។

ដានី ៖ គណៈស្រុកនៅណា?

ម៉ាលី ៖ គណៈស្រុកនៅខាងពោធិ៍សាត់ នៅខាងបាកាន ។

ដានី ៖ គេដកគាត់ដែរ?

ម៉ាលី ៖ គេដកគាត់តាំងពីនឹង ។

ដានី ៖ ចុះយាយគួប កាលគាត់ពន្ឋាំ គាត់នៅជាមួយ?

ម៉ាលី ៖ បាត់ពីនឹងទៅ គាត់បែកគ្នាដែលគាត់ទៅនៅនឹង ខ្ញុំលែងដឹងចប់ ។

ដានី ៖ ចឹងអ៊ំនៅរហូតដល់ពេលដែល អឺ!យួនចូលមកបានរត់មក កាលនឹងជួបជុំប្រពន្ធកូនរត់មកទាំងអស់គ្នាដែរ?

ម៉ាលី ៖ ខ្ញុំជួបជុំទាំងអស់ ។

ដានី ៖ រត់?

ម៉ាលី ៖ អត់ទេ ជួបជុំចេះ ខ្ញុំអត់រត់ទៅតាមខ្សែសង្វាក់គេទៀត ខ្ញុំទៅពីបាត់ដំបងនេះទៅ វៀតណាមមិនចូលពេញកម្ពុជា ។ ខ្ញុំមិនទៅណាខ្ញុំ ខ្ញុំចូលទៅនឹង តែខ្ញុំដើរភ្នំពេញតាំងពីអត់មានមនុស្ស ។ ដើរទៅលេងភ្នំពេញ គ្មានមនុស្សមួយគ្រាប់ទេ ខ្មោចផង ។ រំលងស្ពានចាស់ស្ពានអីផ្ទះថ្មផ្ទះអី មានបងជីដូនមួយនៅនឹង ឈ្មោះ ប៊ិន ។

ដានី ៖ ប៊ិន?

ម៉ាលី ៖ ប៊ិនកាលពីដើម កាលពីសង្គម គាត់ខាងមេព្រៃខាងទឹក គាត់នៅនឹងតាបិន ប៉ុនចែ ។

ដានី ៖ ចឹងឈ្មោះ ប៊ិន នឹង គាត់ធ្វើមេព្រៃតាំងពីជំនាន់ណា?

ម៉ាលី ៖ តាំងពីសង្គមសម្ដេចនោះ ។

ដានី ៖ តាំងពីសង្គមសម្តេច?

ម៉ាលី ៖ ហ្នឹងហើយ ដល់ហើយគាត់នៅភ្នំពេញនោះ ឈ្មោះយាយហឿង ប្រពន្ធគាត់ឈ្មោះយាយហឿង ។

ដានី ៖ ចុះដល់សម័យ៣ឆ្នាំ គាត់អត់អី?

ម៉ាលី ៖ សម័យ៣ឆ្នាំ ដឹងអត់អី តែអត់អីទេបាននៅរស់ ទៅជួបខ្ញុំនៅភ្នំពេញនឹង ។

ដានី ៖ គាត់ត្រូវបងប្អូនតាម៉ុលដែរ?

ម៉ាលី ៖ អឺ! ប្រពន្ធត្រូវបងប្អូន តែប៉ិននឹងគាត់ថ្លៃទេ ។

ដានី ៖ តែដល់ពេលសម័យ៣ឆ្នាំ គាត់អត់អីទេ បានរស់?

ម៉ាលី ៖ មិនដឹងម៉េច ខ្ញុំទៅជួបនឹង ប្រពន្ធគាត់មករកស៊ីជីកអីវ៉ាន់នៅអូរជ្រៅនេះ ហើយខ្ញុំជួបគ្នានឹងក៏ទៅដល់ផ្ទះទៅៗលេងភ្នំពេញ ។

ដានី ៖ ទៅលេងនឹងម៉េចទៀតទៅ?

ម៉ាលី ៖ ទៅលេងខ្ញុំចេញទៅអូរជ្រៅ ខ្ញុំនាំគេរកស៊ី ភ្នំឆ័ត្រចំការគ បារាំងបើកស្រូវ ។ ចេញចឹងទៅ នៅកាប់ចាំងឈើព្រៃ តែគ្រាន់ថាយួនវ៉ៃខ្លាំង បែកខ្ញាំងនេះ ខ្ញុំមកនៅតាឌុកនេះ មកនៅ ម៉ាឡៃនេះ ។ កុំអីមិនធ្វើទ័ពវិញទេ តែមកដល់នឹងកន្លែងជីកជញ្ជូនម៉ង គេហៅប្រជាពលរដ្ឋកងជីកជញ្ជូនស្បៀងឲ្យកងទ័ពមុខៗ ។ ចឹងសម្រាប់ខ្ញុំម្នាក់ ខ្ញុំនឹកឃើញថាអញកំពុងដេកមើលប្រពន្ធអញ គេដាស់ហៅទៅនេះទៅនោះ ដូចជាអាណិតប្រពន្ធណាស់ ។ ចូលទ័ពទៅធ្វើទ័ពរហូត ។

ដានី ៖ កាលនឹងអ៊ំចេញពីបាត់ដំបងអីនឹង អ៊ំចេញពីបាត់ដំបងអ៊ំទៅ ចេញពីភ្នំពេញទៅជួបអីហើយមករកស៊ីវិញ?

ម៉ាលី ៖ ហ្នឹងមករកស៊ី ។

ដានី ៖ រកស៊ីនៅអូរជ្រៅ ជាមួយប្រពន្ធជាមួយអីអ៊ំទាំងអស់គ្នានឹង ទៅមកៗជាមួយគ្នា?

ម៉ាលី ៖ ទាំងអស់ បាទ!

ដានី ៖ ចឹងអ៊ំចាប់ធ្វើទ័ព ពីឆ្នាំណា?

ម៉ាលី ៖ អើយ! មកធ្វើទ័ព៨០ប៉ុន្មាននេះទៀត មើល៨៦ អូ!មិនមែនទេ ៨៣ ។ គេបញ្ជូនកាលនឹងបែកចំការគរ ៨៥ អូ! ៨៦បានធ្វើទ័ពទៀត ។

ដានី ៖ អូ! ទៅរកស៊ីបានយូរទៀត?

ម៉ាលី : ហ្នឹងហើយ ។

ដានី : ដល់ពេលធ្វើទ័ពៗជាមួយតាកន?

ម៉ាលី : ធ្វើទ័ពជាមួយតាកននេះ ។

ដានី : ពេលអ៊ំធ្វើទ័ព អ៊ំមានតួនាទីអីដែរ?

ម៉ាលី : អើយ! ធ្វើទ័ពនឹង គ្រាន់កងគេ កងវរៈគេមួយ អាទ័ព ។ ដូចកងវរៈមួយៗមិន២០០-៣០០ ប៉ុនកងវរៈយើងសម័យនោះ៥០-៦០នាក់ ។

ដានី : ចឹងអ៊ំកងវរៈ?

ម៉ាលី : បាទ! កងវរៈកាលនឹង ។

ដានី : ចឹងអ៊ំប្រធានកងវរៈសេនាតូច?

ម៉ាលី : បាទ! វរៈសេនាតូច ។ កងវរៈសេនាតូចវាឯករាជ្យចេញពី៦៨នេះ ។

ដានី : តាកន កងពល?

ម៉ាលី : កងពល ។

ដានី : អ៊ំវរៈលេខប៉ុន្មាន?

ម៉ាលី : ២៥០ហើយ កាលនឹង ។

ដានី : វរៈសេនាធំលេខប៉ុន្មាន?

ម៉ាលី : អានេះអត់មានធំទេកាលនឹង ចេញពីតាកនម៉ង ។

ដានី : អូ! វរសេនាតូចឯករាជ្យ?

ម៉ាលី : បាទ! ឯករាជ្យ ចេញពីតាកនម៉ង ។

ដានី : ចឹងកូនទាហានអ៊ំមានប៉ុន្មាននាក់?

ម៉ាលី : កូនទាហានខ្ញុំ៥០នាក់ កាលនឹង ៥០នាក់មួងយូរៗបាត់នៅតែ៤០ ៣០ចឹងទៅ ។

ដានី : អត់គ្រប់ៗនេះវា?

ម៉ាលី : អត់គ្រប់នេះទេ កងវរៈកាលនឹង ។

ដានី : ទាល់តែ២០០-៣០០?

ម៉ាលី : ៣០០ជាង ។

ដានី : ប៉ុន្តែមានតែ៥០?

ម៉ាលី : មានតែ៥០ យើងបូកបានតែ៥០ ជិតចូល៦០ ។

ដានី : ចឹងទៅវៃណាខ្លះទៅ?

ម៉ាលី ៖ ហ៊ើ! ទៅវៃអំពិល៥ដើម ទៅក្នុងៗចូលទៅបាត់ដំបង ចូលអីចឹងទៅ កាលណានេះចូលចឹងទៅ ។

ដានី ៖ វៃខ្លាំងដែរ កងទ័ពអី?

ម៉ាលី ៖ ហ៊ើ! កាលនឹង អូ!ចឹងកាលដល់សម័យនឹងចេះតែអួត ។

ដានី ៖ អ៊ីដូចថាអ៊ីយើងវរៈឯករាជ្យ ទាល់តែខ្លាំងបាន?

ម៉ាលី ៖ នឹងហើយទៅវៃមួយៗចឹង បានកូនទាហានរស់ចោលអស់ វាជាប់នៅទាល់តែ ប្អូនថ្លៃខ្ញុំស្លាប់នៅភ្នំយើងនេះ ។

ដានី ៖ អ៊ីតួនាទីគណៈវរៈអីចឹង យើងអត់បានទៅសមរភូមិ?

ម៉ាលី ៖ ហ៊ើ! នៅជាប់នឹងម៉ង ។

ដានី ៖ នៅជាប់នឹង?

ម៉ាលី ៖ នៅនឹងអត់មានចេញមកក្រៅបាន ។ ត្រឹងកងវរៈសេនាធំ វរសេនាតូចអី គឺនៅក្នុងសមរភូមិម៉ង ។ បើមានការអីស្រែកតាមតេអូ ឲ្យកូនទាហានមកមានអ្នកកម្មាភិបាលមួយចំនួនបញ្ជូនឲ្យទេ បើបញ្ជូនឲ្យទៅអត់ទៅ បើអត់ទៅៗយើងនៅនឹង ។

ដានី ៖ ចាប់ពី៨៥ ៨៦?

ម៉ាលី ៖ បាទ!៨៦រហូត ។

ដានី ៖ ចាប់ពី៨៦នឹង?

ម៉ាលី ៖ បាទ! ៨៦នឹងរហូត ។

ដានី ៖ ចាប់ពី៨៦នឹង?

ម៉ាលី ៖ អឺ! រហូតមកដល់ ។ កើតរឿងមួយទៀត តាកនដាក់គុកម៉ាសារទៀត ថ្មីៗដល់យើងចប់វៃសង្គ្រាមនឹង ៨៦នឹង ស្អី៨៦ ៨៧ ខ្ញុំមានរឿងនៅ ។ បើមិន៨៨ ៨៩នឹង អារឿងនឹងចេះ ទ័ពខ្ញុំទៅមុខអស់ទៅ មានម៉ាចំនួនវារត់មកក្រោយៗ ខ្ញុំតាមមកនិយាយរឿងស្អីទេ កាលនឹងចោរប្លន់ដំរីនោះ អាចោរប្លន់នឹងមិនដឹងជាខាងណាទេ គេថាកងខ្ញុំនឹងទៅប្លន់ ចឹង បានទំនាស់គ្នាខ្ញុំអត់ទៅមុខ ។

ដានី ៖ ទំនាស់ជាមួយអ្នកណា?

ម៉ាលី ៖ ទំនាស់ជាមួយកងវរៈគេកាលនឹង មានកងវរៈគេមួយនៅជិតខ្ញុំ កន្លែងជិតគ្នាមួយដែរ ។

ដានី ៖ ឈ្មោះអីគេ?

ម៉ាលី ៖ អានឹងសាប់បាត់ហើយ តារុំៗ នៅខែ១៩៧ ខ្មោចតាហឿននោះ។ ចឹងខ្ញុំអត់ទៅៗចាប់តាមរឿងបួនជំរំនេះ ចឹងអត់ទៅមានរឿងបណ្ដោយ ។ មានរឿងបានគេចាប់ខ្ញុំដាក់គុកនេះ អាក្មួយខ្ញុំនៅនេះ ខ្ញុំទៅសួរអាមេគុកនឹង តាចាន់ ខ្ញុំសួរថា«ចាប់ខ្ញុំ ខ្ញុំចង់ដឹងពីទោសអីទេ ត្រង់ដាក់អីដាក់ គេដាក់ទាំងប្រពន្ធទៀត ប្រពន្ធក៏ទៅគេដាក់ឃ្នោះ ដាក់ឃ្នាសដូចមុនទេ។ ទៅដល់ធ្វើផ្ទះនៅខ្លួនឯងនៅក្នុងគុកនឹងទេ អត់មានអីទេ។ ប៉ុនខ្ញុំចង់សួរថាទោសអីដែលគេយកមកដាក់...ដោះដៃបាននៅនឹងអស់៣ខែ នៅដាំបាយស៊ីនឹង។

ដានី ៖ ប៉ុន្ដែតាកនអ្នកបញ្ជា?

ម៉ាលី ៖ នឹងហើយមេបញ្ជាទៅនឹង។

ដានី ៖ គេចោទអីមូលហេតុអី?

ម៉ាលី ៖ វាអត់ដឹងមូលហេតុ។ ចឹងដល់ខែក្រោយមកខ្ញុំថា ហ៎!បើថាទោសនោះអត់ៗក៏ជិតទៅនៅនឹង។ ខ្ញុំគ្រាន់ថាប៉ុននេះ បើដាក់ទោសអញធូរវៃតិច បើទៅយួនបាញ់សាប់ដដែល មិនបាច់ទៅណាទេ។ ក្រោយមកតាចាន់យើងនឹង គេហៅខ្ញុំទៅជួប ស្មានតែគេដោះលែងខ្ញុំ គេថា«ឥឡូវបេះ លោកឯង» គេហៅលោកតាចាន់នឹងថា «លោកឯងធ្វើតំរួតជាមួយពួកខ្ញុំ មក»ថា«ធ្វើម៉េច បើមនុស្សវាមានទោសនឹង» ខ្ញុំវាប្រហើនចឹងបានបេះជាប់គុកវាផុយនឹង មិនសូវជាបេះខ្លាចអាណាទេ។ ហើយបើធ្វើចឹងៗអត់មានទោសវ៉ាន់ អ្នកណាទៅព្រម ខ្លាច ជាមួយអ្នកឯង «ចុះអត់មានបែងទោសរឿងអីៗ ធ្វើអាដែលតំរួត» ថា«អត់ធ្វើទេ»។ «ហ៎! ថាឲ្យតែថាធ្វើយើងធ្វើទៅមិនបាច់មានទោសមានអី» ទោសគេថាទោសមតិសត្យានុម័តហ៊ុំព័ទ្ធនឹង ចង់និយាយថាពាក្យចចាមរាមថាយើងបេះយើងចុះទៅ គេរួមគ្នាដាក់គុកមួយនឹងទុកទៅ អានឹងគេចង់និយាយបេះ។ អឺ! បើអាចឹងមានទោសទៅ បើឲ្យខ្ញុំធ្វើតំរួតអត់ធ្វើទេ បើថាដោះលែងថ្ងៃណាលែង បើថាមិនកែងដាក់នៅនឹងនៅ។ ដាក់នៅនឹង២-៣ថ្ងៃក្រោយមកគេថា ឲ្យទៅផ្ទះៗវិញមកបណ្ដើរគ្នាមកផ្ទះវិញទៅ។ ផ្ទះខ្ញុំនៅដីថៃនោះ។

ដានី ៖ ផ្ទះនៅដីថៃនោះ?

ម៉ាលី ៖ នៅដីថៃនោះ។ ដល់ត្រូវរបួសឆ្អឹងខ្នងនេះ មិនមែនរបួសតស៊ូហ៎ ត្រូវរបួសខាងក្រោយនេះ យួនកាលនឹងដាក់កាំភ្លើងលើភ្នំព្រីក្សនឹង បាញ់ទៅដីថៃ ជននៅក្នុងភូមិនឹង។ ហើយទៅដល់កន្លែងនឹង ខ្ញុំវាចាស់ទុំជាងគេ សម្រាប់មើលក្មេងៗអាប្រពន្ធទាហានប្រពន្ធយោធា ដែលទៅមុខអស់នឹង ត្រូវគ្រាប់ប្លោងទៅ ខ្ញុំថាឲ្យគេចេញអស់ហើយ។

ខ្ញុំវានៅឲ្យចិញ្ចឹម មាន់ អីៗគេអត់ប្រើទៅណា ចិញ្ចឹមមាន់ដល់ពេលផ្ទុះទៅមាន់ដល់មាន់អីនឹង ទៅដល់ចាប់ មានគេប្ញោងមកគ្រាប់ប្ញោងគេទៅត្រូវរបួសទៅ ឲ្យប្រពន្ធទ័ពរត់ចេញមក ឯងនៅត្រេ ត្រាល់នៅនឹង របួស ។

ដានី : ចុះអ៊ំកាលជំនាន់នឹងនៅដីថៃ យើងអត់នៅនេះទេ?

ម៉ាលី : អត់នៅនេះទេ ។

ដានី : ហេតុអី?

ម៉ាលី : នៅម៉េចបាន កន្លែងនេះព្រៃងងឹតឈឹង ហើយកាលនឹងយួននៅប្រឡោះនេះ ។

ដានី : យួនចូលមកដល់នឹង?

ម៉ាលី : នោះអាប្រេក អាមុខផ្ទះខ្ញុំ អាកន្លែងដែរគេកាយប្រើននឹងបន្ទាយគេនឹង វ៉ៃគ្នាត្រង់នឹង ។

ដានី : កាលពីមុនយួនចូលយើងនៅនឹង?

ម៉ាលី : នៅនឹងនៅដីថៃនឹង ពួកអ្នករត់ ខ្ញុំរត់តាមផ្លូវលើចឹង តាមប្រេកតាមជំរំបេះ ។ ខ្ញុំមិនមែនពួករត់តាមពីនេះ ដូចខ្ញុំនិយាយមិញទៅភ្នំពេញទៅអីរកស៊ីបេះៗ មកចឹងមកទៅធ្វើទ័ពនៅនឹងលើនឹង ។

ដានី : ដល់ពេលអ៊ំចេញពីគុកមកវិញ អ៊ំអត់ធ្វើកងទ័ពទៀតទេ?

ម៉ាលី : អត់ធ្វើ ។

ដានី : ម៉េចចឹងបានឈប់ធ្វើ?

ម៉ាលី : ចុះកាលនឹងវា៩១ហើយ គេថាឈប់វ៉ៃ គេចចារគ្នាអីណា របួសផងរបួសថ្មីបេះ កាប់ព្រៃនៅសព្វថ្ងៃ ។ ប៉ុនអន្ទុរកាកបាទបើកឲ្យ នឹងកាកបាទបើកមកដឹកយកមកដាក់ ។

ដានី : ចុះអ៊ំជួបតាម៉ុកពីអន្លង់?

ម៉ាលី : ជួបកាលដែលគេមកវ៉ៃម៉ាឈុលដែលនេះនឹង ម៉ាឈុលដែលខ្ញុំមកនៅភ្នំព្រឹក្ស ។ អានឹងគេហៅថាអី អៀង សារី ហើយប៉ុលពតម៉េច អត់ត្រូវគ្នាម៉េចនោះ ។ នឹងមិនកាលនឹងប៉ៃលិនគេបះបោរ យើងបះបោរ អាកងទ័ពកំពុងវ៉ៃជាមួយពីក្នុងទៅផងចឹងបានគេវ៉ៃ ។ ដល់ក្រោយមកឈប់វ៉ៃក្នុង មកវ៉ៃគ្នាឯងនេះ នឹងតាពង់ តាអីគេបំផុសកម្លាំង ។

ដានី : កែវ ពង់?

ម៉ាលី : ហ្នឹង! កែវ ពង់នឹង បំផុសកម្លាំងកាលនឹងបំផុសកម្លាំងតស៊ូ អាគ្នាតូចៗនឹងអត់វ៉ៃគ្នា តែអាធំៗឲ្យវ៉ៃគ្នាណា អានឹងចឹង ។

ដានី ៖ ចឹងពីមុនមកអត់ដែលជួបតាម៉ុកទេ?

ម៉ាលី ៖ អត់ដែលជួបទេ ទើបជួបម៉ាឆុលដែលវៃគ្នាចប់ តាម៉ុកចុះមកបណ្ដោយ ។

ដានី ៖ ចឹងក្រោយអីជាប់គុកហើយ?

ម៉ាលី ៖ ហ្នឹងហើយ ។

ដានី ៖ ចុះតាសុន សេននៅណា?

ម៉ាលី ៖ សុនសេននៅជាមួយតាកននឹងម៉ឺង បញ្ជាឲ្យផ្ទាល់នឹង ។

ដានី ៖ តាសុនសេនគាត់នៅណា?

ម៉ាលី ៖ នៅ៣២ នៅជាមួយតាកន ។

ដានី ៖ អានឹងគេហៅ៣២?

ម៉ាលី ៖ ហៅមន្ទីរ៣២ ប៉ុនមិនដែលឃើញអ្នកណាឃើញមុខទេ សុន សេននឹង ។

ដានី ៖ អត់ដែលឃើញ អ៊ំអត់ដែរឃើញទេ?

ម៉ាលី ៖ អត់ដែលឃើញទេ ទើបឃើញតាម៉ុកមកប្រជុំទើបឃើញ ហៅមកជួបជុំគ្នាខ្ញុំឃើញ ។

ដានី ៖ ចឹងកន្លែងនេះកងពល៦៨?

ម៉ាលី ៖ នឹង៦៨ ។

ដានី ៖ កងពល៦៨ពីត្រឹមណាដល់ត្រឹមណា?

ម៉ាលី ៖ ទេ! បើកាលពីកម្លាំង៦៨ពីប៉ៃលិនមក តែដល់សុនសេនមក មិនដឹង៦៨ត្រឹមប៉ុន្មានទៅ ត្រឹមប៉ុន្មាន បែកគ្នាទៀត ខ្ញុំលែងធ្វើទ័ពហើយ ។

ដានី ៖ កងពល៦៨នឹងអត់មានដូរឈ្មោះអីទេនៅរហូត?

ម៉ាលី ៖ នៅរហូត ។

ដានី ៖ ចុះ៣២០?

ម៉ាលី ៖ ៣២០អីនឹងជាកងវរៈតូច កាលពីដើម៣២០ ៣៩១ ៦១អីណាណោទេច្រើន ។

ដានី ៖ ប៉ុន្តែកងពលធំកងពល៦៨ទេ ។

ម៉ាលី ៖ ៦៨ ។

ដានី ៖ តាកន គាត់អ្នកគ្រប់គ្រង?

ម៉ាលី ៖ តាកន គ្រប់គ្រង ។

ដានី ៖ សុន សេន គាត់នៅនឹងដែរ?

ម៉ាលី ៖ សុន សេន មកបញ្ជាពីលើ៦៨ទៀត ។

ដានី ៖ មកបញ្ហាពីលើនឹងទៀត?

ម៉ាលី ៖ លើនឹងទៀត ។

ដានី ៖ ចុះពូមីងម៉ាចំនួនកាលនឹងគាត់នៅខាងអូររំដួល គាត់ថាសុនសេនគាត់បញ្ហាកាលឆ្នាំ៩០ ជាងអីនឹង គាត់ថាឲ្យបញ្ហាយកទ្រព្យសម្បត្តិទ្រព្យអីដាក់រួមដាក់អីនឹងយ៉ាងម៉េចដែរ?

ម៉ាលី ៖ អួយ! ជិនាន់នឹងហើយតាម៉ុកគាត់ចុះ អើយ!កាលនឹងឆ្នាំប៉ុន្មានទេ គាត់ដកគោ ដករទេះប្រជាពលរដ្ឋយកទៅបាត់អស់ មិនដឹងយកទៅដាក់រួមណា ។ តាម៉ុកមកបានដកយកមកខ្លះវិញ ឆ្នាំប៉ុន្មានទេ ។

ដានី ៖ បចារនៅ ដូចថាកិច្ចព្រមព្រៀងក្រុងបារីសឆ្នាំ?

ម៉ាលី ៖ ៩៣ ។

ដានី ៖ ៩១ គេបោះឆ្នោតឆ្នាំ៩៣ បោះឆ្នោតខាងក្នុង?

ម៉ាលី ៖ មុនៗ ។

ដានី ៖ មុនបោះឆ្នោត?

ម៉ាលី ៖ អឺ! នឹងជួបៗថ្ងៃតាម៉ុកចុះមកដកហូតដកអីប្រជាពលរដ្ឋនឹង ។

ដានី ៖ កាលនឹងម៉េចដែរ ម៉េចបានដកចឹង គាត់ថាចឹង?

ម៉ាលី ៖ ទេ! ខ្ញុំអត់យល់ កាលនឹងគេថាសុន សេនមកប្រមូល សូម្បីកាបព្រៃម៉ាប្រ៉ក់ក៏មិនបាន ។

ដានី ៖ ប្រមូលអស់ទាំង?

ម៉ាលី ៖ គោរទេះ ។

ដានី ៖ គោរទេះ របស់របរ យកទៅណាណា?

ម៉ាលី ៖ យកទៅណា ថាយកទៅបាត់ទៅ ដើរទិញតាមណា ។

ដានី ៖ កាលនឹងប្រជាពលរដ្ឋ ដូចកងទ័ពអីនៅនឹងមានម៉េចដែរ គាត់ពេញចិត្តឲ្យប្រមូលឬក៏ម៉េច?

ម៉ាលី ៖ អារឿងនឹងចឹង របបខ្មែរក្រហមថាពេញចិត្តមិនពេញចិត្តត្រូវគេធ្វើបានអានឹងចឹង បើថាឲ្យពេញចិត្តគ្មានអ្នកណាពេញចិត្តទេ ក្នាបានរទេះគោមួយរកស៊ី ។ មិនពេញចិត្តហើយបានតាម៉ុកមក ប្តឹងតាម៉ុកនឹង តាម៉ុកដក បានរទេះគោខ្លះមកវិញ ។

ដានី ៖ ចឹងតាម៉ុកមកឆ្នាំណា?

ម៉ាលី ៖ តាម៉ុកឆ្នាំណាដែរគាត់មកនឹង ថ្ងៃជួបរដ្ឋប្រហារនឹង ៩៣ដឹង៩០ប៉ុន្មានភ្លេចឆ្នាំហើយ... ។ ព្រោះ៩១យើងចុះមកនៅសង្រ្គាមនឹងហូរហែលទៅ៩៦ ។

ដានី ៖ ៩៦?

ម៉ាលី :	៩៦បាទ! ៩៦ផ្តាច់ខ្លួន ៩៦ថ្ងៃផ្តាច់ខ្លួនមាន ។

ដានី :	ចឹងសុន សេន គាត់ឲ្យប្រមូលរួមនឹងឆ្នាំណា?

ម៉ាលី :	ឲ្យម៉ាឆ្នាំមុននឹងហើយ ៩៥នឹង ៩៦បានផ្តាច់ខ្លួន តាម៉ុកមក ។

ដានី :	តាម៉ុកមកជួបជុំពីណាខ្លះ?

ម៉ាលី :	ជួបជុំប្រជាពលរដ្ឋតាមនឹង ។

ដានី :	ប៉ុន្តែអ៊ីមានប្រសាសន៍មិញថា តាម៉ុកមក, អៀង សារី, លែវ ពង់ ជួបជុំ ប្រជុំពីអន្លង់?

ម៉ាលី :	អត់ទេ ដែលជួបជុំនេះតាម៉ុកទេ ហើយនឹងសុន សេន ។ ដែលខ្ញុំនិយាយកែវ ពង់កែវអីម៉ាហ៊ឹងនឹងផ្តាច់ខ្លួននឹងកែវពង់វៃពីណា ឡែមមក ។ អានឹងកង៍ទ័ពគេថយមក ហើយតាម៉ុកចេះថយៗរហូតដីថៃ ។ ចឹងបានការសិក្សានិយាយពេលនឹង បានបងប្អូនណានិយាយ បើសគ្រាមដេញទិស គាត់ទៅប៉ៃលិនមកៗដាប់រហូតបះបោរមកចឹងម៉ង ផ្តាច់ខ្លួននឹង ។

ដានី :	អ៊ីជួបតាម៉ុកពេលណា?

ម៉ាលី :	ជួបពេលដែលខ្ញុំកំពុងនិយាយនឹង  និយាយដែលគាត់ដើរៗគេកំពុងវៃបណ្តើរជួបទៅចចារអ៊ឺ!ទៅជួបនៅ៣២ ។

ដានី :	៣២ ឆ្នាំណា?

ម៉ាលី :	ហ្អឹង៩៦ហើយ ។

ដានី :	ជួបគាត់ថាម៉េច?

ម៉ាលី :	ជួបប្រជុំប្រជាពលរដ្ឋទូទៅទាំងអស់នឹង អាខ្លះប្តឹងយកគោ ខ្លះប្តឹងពីអីគាត់ដោះស្រាយ វាមិនបានសិក្សានិយាយគ្នាណា ។ គាត់ពន្យល់តស៊ូត្រូវវៃអីនៅណា យើងជាប្រជាពលរដ្ឋមួយទៅស្តាប់ទាំងអស់គ្នា អានឹងគ្រាន់ចឹង ។ អានឹងគាត់ដឹងថាឃើញយើងៗឃើញគាត់ដឹងថាបងប្អូននៅនេះនៅនោះតែប៉ុននឹងទេ ។ តែអាការនិយាយស្តី និយាយជារួម ។

ដានី :	គាត់និយាយជារួម គាត់ថាម៉េច?

ម៉ាលី :	មិត្តត្រូវទៅតស៊ូអី ដាក់អីស្កាត់យួនអីណាចឹង ។ មានយួនណា សុទ្ធតែខ្មែរមានអ្នកណាទៅ ធ្វើៗ ដល់ចឹងទៅគាត់ចេញទៅដីថៃ ជាមួយសុន សេន ទៅបាត់ទៅតាកននឹងក៏ទៅដែរ តែពីណាគេអត់ឲ្យចូលប្រទេសថៃ ដាក់ពីណាវិញ បានគេយកមកដល់នេះវិញ តាកន ។

ដានី :	ចឹងម៉េចបានគេដាក់?

ម៉ាលី ៖ ហ្នឹងហើយសុំទៅនឹងគេដែរ ទៅប្រទេសក្រៅ ប៉ុនថាទៅអត់រួច បកមកវិញ ។ បកមកវិញយកផ្ទះនេះវិញ ។

ដានី ៖ អូ! តាម៉ុក ហើយសុន សេនទៅកើត?

ម៉ាលី ៖ ទៅបាត់ឆ្ងាយណានោះ និយាយទៅវិលក្បាលពេញនឹង ។ ចឹងបានខ្ញុំតស៊ូជាមួយខ្មែរក្រហមដែរនឹង ប៉ុនគ្មានគុណសម្បត្តិ មានតែថ្ងៃគ្មានទោស អត់មានរឿងអីថា៣ឆ្នាំ១ចុះ ។ ប៉ុនដល់អា៧០សង្គ្រាមជាមួយយួននេះ ដែលតុបតើបជាមួយគ្នានេះ ទៅជាឯងមានមានទោសណាដាក់គុករកកន្លែងទោសអត់ឃើញទៀត ចឹងតាមដំណើរ ។

ដានី ៖ តាម៉ុកគាត់ជួយ?

ម៉ាលី ៖ ហ៎! តាម៉ុកមានដឹងខ្យល់អីណា នៅណានោះ ខ្ញុំក៏មិនដឹង គាត់ក៏មិនដឹង ខ្ញុំមិនទៅរកសូម្បីតែម៉ុក ម៉ារ៉េត នៅរាល់ថ្ងៃ អាក្មួយនោះឲ្យមកជួប ខ្ញុំថាហ៎!គេរស់គេ គ្មានពិបាកស្អីទេ ។

ដានី ៖ ម៉ុក ម៉ារ៉េតត្រូវជា?

ម៉ាលី ៖ អឺ! ហ្នឹងហើយជីដូន ជីទួតមួយដែរនឹង ។

ដានី ៖ ត្រូវជីទួតមួយដែរ?

ម៉ាលី ៖ នឹងហើយ ។

ដានី ៖ តែអត់ដែលជួបទេ?

ម៉ាលី ៖ អត់ដែលជួបទេ ឮឈ្មោះរៀងខ្លួន ទៅភ្នំពេញដែរ គេបបួលទៅជួបថា ហ៎!គេធំៗហើយមិនបាច់ជួប ។

ដានី ៖ អត់ដែលជួប ម៉េចបានអត់ទៅជួបគាត់?

ម៉ាលី ៖ ទេ! មុខងារខុសគ្នា ។

ដានី ៖ ដែលយើងទៅដូចថាក្នុងនាមបងប្អូន ចុះពេលបុណ្យដែលយើងរដូវបុណ្យអីនៅស្រុកភូមិអីអត់ដែលទៅ?

ម៉ាលី ៖ ស្រុកភូមិអត់ដែលទៅ ស្រុកនឹងអត់ដែលទៅទេ ត្រពាំងធំតាំងពីចប់សង្គ្រាមមកអត់ ដែលទៅទេ ទៅមួងដល់ត្រឹមអង្គតាសោម មកវិញមក ។

ដានី ៖ ចុះម៉េចអត់ទៅស្រុក?

ម៉ាលី ៖ មិនដឹងម៉េច មិនសូវចូលចិត្តទៅមិនស្រួល ពិបាកសួររឿងស្រុកខ្ញុំ ចំណាំមនុស្សរួចប់ ។

ដានី ៖ ជិតចប់ហើយ ។ អ៊ំបន្ទាប់ដូចថាកាលជំនាន់នឹង យើងប្រទាញប្រទង់អ៊ំ ខាងប៉ៃលិន ខាងម៉ាឡៃអី ដូចថាសមាហរណកម្មជាមួយរាជរដ្ឋាភិបាលមុន ហើយខាងនេះមានប្រទាញប្រទង់រកឈ្មោះរកវ៉ៃគ្នាអីទៀតយ៉ាងម៉េចៗ អ៊ំដឹងរឿងនឹងដែរអត់?

ម៉ាលី ៖ ត្រង់នឹងហើយបានតាម៉ុកមកនឹង ។ ដែនការតាម៉ុកគាត់ឲ្យប្រឆាំងគ្នា តែកងទ័ពយើងនេះយល់ថាមិនប្រឆាំង វាអត់អីទេ អ្នកនៅបញ្ចូនពី៣២នេះទៅនៅឯជើងនោះនៅនឹងទៅ ។

ដានី ៖ នៅម៉ាឡៃ?

ម៉ាលី ៖ អឺ! នៅម៉ាឡៃនៅនឹងទៅ អាបះបោរវ៉ៃគ្នាណាទៀត មិនមែនតែរឿងរត់ទេ ពីត្បូងគេបោសសំអាតមក គេហែលគ្នាមកកាំភ្លើងប្រូងប្រាំងៗរត់ បេះទៅៗ ។ មានមេ២នាក់បេះនាំគ្នារត់ទៅ មានអាតាម៉ុក តាសេននឹងបេះបណ្ដើរគ្នាទៅណាទៅបាត់ទៅ ។ មានតប់គ្នាអីម៉ាគ្រាប់ អត់មាន ។

ដានី ៖ ចឹងកាលតាម៉ុក សុន សេន បញ្ជាឲ្យវ៉ៃ ប៉ុន្តែកងទ័ពអត់វ៉ៃ?

ម៉ាលី ៖ អត់វ៉ៃ ប្រជាពលរដ្ឋមិនវ៉ៃ ទ័ពមិនវ៉ៃ ។

ដានី ៖ ចុះដល់ក្រោយមកទៀត ដល់ពេលតាមដឹងថាសុន សេនទៅដល់អន្លង់វែងគេសម្លាប់ទាំងក្រុមគ្រួសារ ទាំងគាត់ អ៊ំដឹងដែរអត់?

ម៉ាលី ៖ អានឹងអត់ដឹងរឿង ។

ដានី ៖ ពីណាសម្លាប់ខាងណា សម្លាប់គាត់ អ៊ំអត់?

ម៉ាលី ៖ អត់ ដឹងគេយកទៅធ្វើម៉េច ។

ដានី ៖ ចឹងអ៊ំដូចថាចាប់ផ្ដើមនៅកន្លែងនឹង អ៊ំមានប្រសាសន៍មិញថា អ៊ំធ្វើប្រធានភូមិតាំងពីឆ្នាំ ១៩៩១?

ម៉ាលី ៖ ៩១ ។

ដានី ៖ ចឹងតាំងពីនៅប្រទាញប្រទុង នៅឈ្លោះគ្នានឹង អ៊ំនៅធ្វើប្រធានភូមិគ្រប់គ្រងនៅភ្នំព្រឹក្សនឹង?

ម៉ាលី ៖ នៅតែនឹង ។

ដានី ៖ តាំងពីចូលមកនៅនឹង នៅធ្វើប្រធានភូមិរហូត?

ម៉ាលី ៖ រហូតនឹង ចាស់ទុំដាងគេ គេឲ្យធ្វើចឹង ។

ដានី ៖ អ៊ីមួយទៀតដូចថា នៅស្រុកភូមិយើងចឹង កាលនឹងសុទ្ធតែព្រៃ សុទ្ធតែអី អត់មានឈ្មោះអីដូចឥឡូវ ភ្នំព្រឹក្ស អីភូមិអីអូរស្រឡៅ ភូមិអីហូរហែលចឹង យើងដាក់ឈ្មោះយ៉ាងម៉េច កាលនឹងសុទ្ធតែព្រៃ?

ម៉ាលី ៖ អឺ! កាលពីដើមមក គេហៅថាតំបន់នេះ មានអូរបោទមួយៗនឹងមិនដឹងនៅកន្លែងណាទេ បើគិតទៅតាំងពីបារាំង បើទៅដល់ដើងបារាំងធ្លាក់ ចក្រី វាមានភ្នំវាៗ ដល់ត្រង់នេះគេហៅអូរបោទ ដល់កំពូលនេះគេហៅភ្នំព្រឹក្សៗ ចឹងគេហៅថាអូរបោទ ភ្នំព្រឹក្ស បារាំងធ្លាក់ចឹងទេៗ ដល់នេះគេចែកជាឃុំគ្នា ចឹងបាននៅក្នុងស្រុកនេះវាមានភូមិចក្រី ឃុំភ្នំព្រឹក្ស ហើយក្នុងឃុំនីមួយៗមាន៥ភូមិ ចែកភូមិគ្នា ចឹងបានភូមិនៅលើភ្នំគេដាក់ភ្នំព្រឹក្សៗ ភូមិនៅម្តុំនេះសំបូរដើមបេង គេដាក់បេងស្អាតចឹងទៅៗ ហើយអាដើមស្រឡៅច្រើននោះទួលខ្ពស់នោះ អានឹងគេដាក់តាមដីតាមទឹកគេទៅ ភាសាគេប្រើជាប់រហូតទៅៗ

ដានី ៖ ចឹងយើងអ្នកដាក់ យើងអ្នកសម្រេច?

ម៉ាលី ៖ បាទ! យើងសម្រេចតែគ្នាយើងៗ

ដានី ៖ ពីឆ្នាំណាមក?

ម៉ាលី ៖ អានឹងចប់ពីរៀបចំ អានឹងសមាហរណកម្មហើយ យើងរៀបចំភូមិឃុំតាមនេះទៅ បានច្បាប់រៀបចំឲ្យគ្រប់គ្រងភូមិឃុំនឹងៗ

ដានី ៖ ពី៩៦ ៩៧ហើយ?

ម៉ាលី ៖ បាទ! ៩៦ ៩៧ រៀបចំនឹងទៅ យើងខាងច្បាប់នឹងដាក់ពីក្រោយទៀតមក ទទួលខុសត្រូវគ្នាៗ ចឹងបានសព្វថ្ងៃអត់មានដេញចេញចូលនៅណា អ្នកណានៅណានៅនឹង ស្រួលដាក់តែភូមិទៅហើយនៅបណ្តោយៗ

ដានី ៖ ចុះអ៊ំបើតាមអីដូចថាអ្នកគ្រប់គ្រងនៅស្រុកភូមិនឹង ដូចថាតាំងពីមុនសមាហរណកម្ម ហើយក្រោយសមាហរណកម្ម មានការខុសប្លែកគ្នាយ៉ាងម៉េច ស្រុកភូមិយើងមានការប្រែប្រួលខុសប្លែកយ៉ាងម៉េច?

ម៉ាលី ៖ វាខុសប្លែកច្រើនណាស់ប្អូន ព្រោះកាលពីមុននោះវាមានការលំបាកច្រើនមែនទែន ទី១ព្រៃ ស្តុកដង មានឈើ មានដានោះខ្លាំង ហើយគ្មានពេទ្យ គ្មានហ៊ូរីងមាំទេៗ ចឹងបានការស្តុក ស្មាញកន្លងនោះវាច្រើនៗ ហើយដល់បច្ចុប្បន្ននេះ យើងនិយាយពីរាជរដ្ឋាភិបាលរបស់ យើងវាមានច្បាប់ជាពិសេសមួយពីរទៀតធនធានមនុស្សច្បាប់របស់រដ្ឋ គេចែងមក មនុស្សចេះគោរពគ្នា

រស់នៅកាលពីមុនថាថ្នល់តូច ឥឡូវនឹងបានថ្នល់ធំទៀតរិតតែភ្លឺថ្លា មែនទែនដូចស្រស់ថ្លា ។ មិនទាន់ថ្នល់ផង គ្រាន់តែជិះម៉ូតូវៀងរំភើយដែរ មិនអីទេចឹងបានធូរស្រាលច្រើន ។ រីឯសុខភាពប្រជាពលរដ្ឋ បន្ទាប់ពីមានក្រសួងនានាខាងសុខាភិបាល ខាងអីមកគេជួយជាប់រហូត ខាងសិទ្ធិមនុស្សខាងអី គេជួយអប់រំទៅគ្រាន់បើ ។

ដានី : បើគិតទៅតាំងពីជីវភាព ទាំងសុខភាពយើងមានការរីកចំរើនគ្រាន់បើជាងមុ ឬក៏ម៉េច?

ម៉ាលី : គ្រាន់បើជាងមុន គ្រាន់យកមែនទែន វាមាននាយទុន គេហៅថាក្រុមហ៊ុនច្រើនទៅយើងរកស៊ីបានធូរធា ។

ដានី : មួយទៀត តាមខ្ញុំជួបអ៊ំពូមីង គាត់នេះម៉ាចំនួន នៅតាមនឹង ម៉ាចំនួនតូចគាត់និយាយថាដូចកាលពីមុនសមាហរណកម្ម គាត់រស់នៅមិនចាំបាច់ខ្វាយខ្វល់ ទៅរកស៊ីរកអី យើងគិតតែតស៊ូអីទៅយើងមានរបបគ្រប់សព្វអង្ករ ប៊ីចេង ត្រីខ មួបអីនឹង មានហូបចុកគ្រប់គ្រាន់ ។ ដល់ក្រោយមកនឹង គាត់ថាដូចថាពេលខ្លះមានការពិបាកជីវភាព យើងត្រូវទៅរកអីខ្លួនឯងបានហូប បើសិនរកមិនបានពិបាកលំបិនអីចឹង អ៊ំយល់ម៉េចដែរ?

ម៉ាលី : បើតាមខ្ញុំគិតអ្នកនិយាយមួយរបស់គាត់មួយគ្រួសារទេ មិនសំខាន់ទេ ។ ព្រោះគាត់ថាធូរទៀត បានន័យថាគាត់រស់នៅសង្ឃឹមថាគេបើកឲ្យហូប ចឹងគាត់គិតខ្លីៗ គេឲ្យប៉ុន្មានហូបប៉ុន្មានហូបប៉ុននឹងហើយស្រួលហើយ យើងអត់ដឹងថាកូនចៅអនាគតគាត់យ៉ាងម៉េច គាត់អត់បានគិត ខ្ញុំថាតិច ហើយគាត់គិតខុសទៀត ។ គិតធម្មតា៣ឆ្នាំបើឲ្យម៉ាវែកហូបម៉ាវែក ផាប់អស់ហើយ ។ អាកូនកើតមកនៅតែម៉ាវែក ហើយយើងនឹងទទួលរបបថាគេបើកហូប សុខស្រួល អត់ស្រួលទេ បើខ្ញុំគិត ។ បើយើងមានសិទ្ធិសេរីភាព ពេញសិទ្ធិបរិបូរ ប៉ុននេះ ពិបាកហើយ បើមិនខំធ្វើម៉េចបើនៅឲ្យស្ងៀមឲ្យគេបើកឲ្យហូប គេម៉េចបើកឲ្យ ។ ទាល់ តែពើតដីចំការនៅគាត់អត់គាត់ទេ គាត់ថា តែបើខ្ញុំយល់គាត់ថាគាត់គិតខុស ប៉ុនអានឹងក្រែងខ្ញុំគិតខុសមិនដឹង ។

ដានី : ខ្ញុំអត់ដឹងតែ តែគាត់មានយោបល់ចឹង សួរយោបល់អ៊ំៗជាអ្នកដឹកនាំ?

ម៉ាលី : បាទ! ខ្ញុំថាគាត់គិតខុស ។

ដានី : គាត់គិតខុស?

ម៉ាលី ៖ ហើយក៏ព្រោះដោយខ្ញុំគេព្រោះគេថាខ្ញុំគិតខុសមិនដឹង អានឹងម្តងម្នាក់ ចាំមើលចាំជួយវិភាគគត ទៀត ។

ដានី ៖ ហើយសំនួរចុងក្រោយ អ៊ីដូចធ្លាប់បានសួររួចហើយ ប៉ុន្តែខ្ញុំចង់សួរយោបល់អ៊ីវិញ ។ ដូចថាសព្វថ្ងៃ ដែលគេខាងរាជរដ្ឋាភិបាល ហើយនឹងអង្គការសហប្រជាជាតិនឹង គេបង្កើតតុលាការដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពី៧៥ ដល់៧៩ នឹង ។ ហើយរាល់ថ្ងៃនេះ ខាងតុលាការគេបានជំរំជម្រះទោសកាំងហ្គេកអ៊ាវ ហៅឌុចដែលជាអតីតប្រធានមន្ទីរសន្តិសុខស-២១ ហៅគុកទួលស្លែងបានជំនុំជម្រះហើយ ។ ហើយខាងមុខឆាប់ៗនេះ គេនឹងចាប់ផ្តើមជំនុំជម្រះទោស មេដឹកនាំជាន់ខ្ពស់៤រូបទៀតដែលមាននួន ជា, ខៀវ សំផន, អៀង សារី និងប្រពន្ធរបស់គាត់ ។ ចឹងក្នុងតាមយោបល់របស់អ៊ីផ្ទាល់ខ្លួន អ៊ីយល់ឃើញថាការបង្កើតតុលាការ ការជំនុំជម្រះពួកគាត់នឹងត្រឹមត្រូវដែរ ឬក៏មិនត្រឹមត្រូវទេ បើតាមយោបល់ផ្ទាល់ខ្លួនរបស់អ៊ី?

ម៉ាលី ៖ ហ៎! បើតាមគិតប៉ុននឹងឯង មិនចេះថាចេះឆ្លើយ ដូចប្អូនមានប្រសាសន៍ចឹង ត្រូវតែមានគំរូអាក្រក់ហើយនិងល្អដើរតួ ខ្ញុំនិយាយខ្លី ។ បើកាលណាអាក្រក់ក៏យើងមិនដើរតួ ត្រូវល្អយើងមិនដើរតួ យើងអត់មានហេតុផលឲ្យក្មេងខាងក្រោយគាត់ដឹងទេ ចឹងការកាត់ទោសនេះគ្រាន់ថា បើនិយាយពីច្បាប់គេយកតែមេៗទេ អ្នកទទួលខុសត្រូវ ប៉ុនដល់ប្រជាជនទាំងអស់ អ្នកធ្លាប់រស់នៅជាមួយក្នុងក្រុមនឹង គេកាត់អាលើហើយគួរតែកាត់អាតូច ។ ប្អូន មានប្រសាសន៍នឹងត្រឹមត្រូវហើយ ប៉ុនខ្ញុំឯកភាពហើយខ្ញុំយល់ថាអ្នកខាងត្រូវតែមាន ទោស ឪពុកចិញ្ចឹមកូន យើងអត់អប់រំកូនខុសគ្រោះថ្នាក់កូនត្រូវឪពុកមានទោសដដែល ចឹងគិតគ្រួសារតូចមួយ ឪពុកនៅមានទោសដែរកូនទៅវ៉ៃគេសួរថាកូនដឹងមិនដឹង បើឪថាមិនធ្វើឪធ្វើអី ។ ចឹងបានមេដឹកនាំគេសរសើនិយាយម៉ាម៉ាត់តិចទៀតចុះ គេថា សម័យពាន្ឆាំសម័យប៉ុលពតមហាលោតផ្លោះអស្ចារ្យត្រឹមត្រូវណាស់ ឃើញឯកសារលក្ខន្តិកៈគាត់ល្អិតមែន ។ ក៏ប៉ុនថាស្តេចនឹងអ្នកល្ងង់ ថាល្ងង់ចុះ ប៉ុនគេសរសើរអ្នកចេះណាស់ថាមិនល្ងង់ បើអត់ដឹងរាស្ត្រហូបបបរផងនឹង ឲ្យយល់ ។ ហើយសុទ្ធធ្លាប់ស៊ីបាយដូចគ្នា ចុះរឿងអីអត់ដឹងរាស្ត្រ បបរ រាស្ត្រអត់បាយ ហើយអង្ករ ដីខ្មែរណាមិនដឹងថាសំបូរសេដ្ឋកិច្ច ហើយស្លាប់ៗ ។ ស្លាប់វ៉ៃចោលម៉ាចំនួនទេ ក្បត់មួយចំនួន អាស្លាប់អត់បាយ

ផាប់អត់ឲ្យស៊ីនេះ អានឹងអត់មិនបាច់រើម៉ឹងផាប់ម៉ឹង ។ ហើយបើនិយាយពីពាស្ត្រសាមញ្ញ គាត់និយាយ គាត់ថាប៉ុលពតសម្លាប់មែន មិនមែនសម្លាប់មនុស្សមានជីវិតទេ អាអត់ជីវិត ក៏សម្លាប់ដែរ ខ្ញុំរកនឹកអត់ឃើញ ។ ចុះការហើយអត់ឲ្យដេកជាមួយគ្នា បានកូនពីណាកើត បានអីរស់ រកនឹកអត់ទាន់ ។ ចុះការហើយប៉ុនអត់ឲ្យដេកជាមួយគ្នា សម្លាប់មនុស្សមហា ជីវិត ។

ដានី : អត់មានការបន្ត(ពូជ) ?

ម៉ាលី : នឹងហើយ ។ ចឹងបានកាត់ច្បាប់មួយនេះវាសមស្របណាស់ ព្រមានឪពុកម្តាយ និយាយគ្រួសារតូចដូចសម្តេចលោកនិយាយមានប្រសាសន៍រាល់ថ្ងៃនឹង កូនឯកឧត្តម កូនលោកជំទាវណាក៏ដោយ ឲ្យតែស្ពឹដាក់គុកឲ្យវាទៅ ។ ចប់ អាកូនវាលែងហ៊ានធ្វើហើយ អានឹងត្រឹមត្រូវរបស់គាត់ហើយ ។ បើមិនចឹងទេ យាយយ៉ត យាយកែវ មានតើ អានឹងជាហូរហែលបោះមកមើលវត្តគេគួរឃើញស្តេចណាម៉េចៗ ឃើញហើយ ដូចមុនីវង្សវ៉ាន់ ។

ដានី : អ៊ឺមានប្រសាសន៍មិញ អ្នកអត់មានជីវិតក៏មានទោសដែរ ចឹងខ្មោចក៏មានទោសដែរ?

ម៉ាលី : អត់ទេ អ្នកមានជីវិតក៏គាត់សម្លាប់ដែរ អ្នកអត់ជីវិតនោះ ។

ដានី : អត់ជីវិតក៏គាត់សម្លាប់?

ម៉ាលី : អឺ! ចុះការឲ្យគ្នា តែអត់ឲ្យគ្នាដេកជាមួយបានកូនពីណាមក ។

ដានី : ជំនាន់នឹងតែជីដូនជីតាក៏មានទោសដែល គ្មានដែលអ្នកណាឲ្យធ្វើបុណ្យធ្វើអី?

ម៉ាលី : នឹងហើយសម្លាប់ទាំងអស់ រហូតដល់អ្នកមើលអត់ឃើញក៏គាត់សម្លាប់បានដែរ អានឹងនិយាយការសម្លាប់ មិនមែនសម្លាប់...(ស្តាប់មិនបាន) អាគ្នាអត់ដឹងអីក៏សម្លាប់បានដែរ ។ ចឹងការសម្លាប់របស់គាត់ ចឹងត្រូវព្រមានគាត់គិច ហើយគេថាមហាអស្ចារ្យ យើងយល់ថា មហាអស្ចារ្យណា បើអត់ដឹងកូនស៊ីអីផង កូនស្លៀកអីផង ។ ចឹងគួរតែព្រមានមនុស្ស ។

ដានី : ហើយចុះអ៊ឹមិនដែលទៅលេងស្រុកកំណើត?

ម៉ាលី : អត់ៗដែរទៅ ។ នៅឪពុកមាបង្កើតមួយនៅនឹងហៅទៅដែរ តែអត់ទាន់ទៅ ។

ដានី : ចឹងអ៊ឹអត់មាននឹកស្រុកអី?

ម៉ាលី : អើ! ដើរក្មេចនឹកអស់ហើយទាំង១៧មក ដើរទៅលេង ។

ដានី : ប្រពន្ធអ៊ឹអត់ដែលទៅដែរ?

ម៉ាលី : យាយខ្ញុំគាត់ធ្លាប់ទៅៗមកហូរហែលរបស់គាត់ ចំឡែកតែខ្ញុំមួយៗចេះតែរកមុខ ។

ដានី ៖ អ៊ំអន់ចិត្តពីណា បានអត់ទៅ?

ម៉ាលី ៖ ហ៎! រឿងអន់ចិត្តមិនអន់អីទេ ប៉ុនតែ ។

ដានី ៖ អត់ចង់ទៅម៉េង?

ម៉ាលី ៖ អត់ចង់ទៅ អត់លុយចាយ យើងមិនសំបូរហូរហៀរ ។ បើសំបូរហូរហៀរ ចេះទៅហើយ

ដានី ៖ អ៊ំដូចថា បើថាអ៊ំមានជីវិភាពធូរធារអីចឹង ចង់ទៅដែរ?

ម៉ាលី ៖ ចង់ទៅដែរ ។

ដានី ៖ តែអ៊ំអត់សូវដោយសារយើងម៉ាគ្រប់គ្រាន់ យើងអត់អ្នកធូរធារអី?

ម៉ាលី ៖ ហ្នឹងចប់សង្គ្រាមមក ប្អូនឯងត្រូវរបួសត្រូវអី មានរកស៊ីខំអីរួច ។

ដានី ៖ ចឹងអ៊ំដូចថាទំនាក់ទំនងជាបងប្អូនអី អ៊ំអត់សូវមានដូចថាទាក់ទងគ្នាអីប៉ុន្មានទេទៅ?

ម៉ាលី ៖ ហ៎! បើបងប្អូនបង្កើតៗវាមករកខ្ញុំ ប្អូនៗមកម៉េងពេញៗតែផ្ទះ ទាំងថ្ងៃ ទាំងបង្កើតអីមក ប៉ុនបានយាយខ្ញុំទេ គាត់ទៅមក ។

ដានី ៖ ដូចថាខាងសាច់ញាតិដូចជាជីដូន ជីតួអី ដូចអត់សូវមានទាក់ទងគ្នាទេ?

ម៉ាលី ៖ ហ៎! បើគេមកជួប ។

ដានី ៖ បើមកជួប?

ម៉ាលី ៖ ជីដូនមួយមកសន្ទឹកសន្ទាប់ ប៉ុនមកខាត មកអស់៤០០ ៥០០ ១០០០ម្នាក់ៗ មកវាទារលុយ មិនចាំបាច់ទៅអី តែមកវាទាញលុយទៅឲ្យកលុយវា ។ បើវាមកចឹងបេះមានលុយឲ្យទៅហើយ បើយើងទៅនឹងអស់ច្រើនទៀត ។

ដានី ៖ ចុះអ៊ំមានមិត្តភ័ក្តអីនៅស្រុកកំណើតអីដូចថា មិត្តភ័ក្តធ្លាប់រៀន ធ្លាប់អីស្របាលៗស្រករៗគ្នា?

ម៉ាលី ៖ អឺ! ស្រករៗគ្នានៅសល់តែមួយ លោកមេឃុំ រៀនជាមួយគ្នាទៅ ។

ដានី ៖ រៀនជាមួយគ្នានៅតាកែវ?

ម៉ាលី ៖ នៅតាកែវ គេនៅលើនេះទេ តែដល់ពេលគេទៅរៀនគេទៅស្នាក់នៅជិតផ្ទះខ្ញុំដែរ ។

ដានី ៖ គាត់មិនមែនស្រុកកំណើតអ្នកត្រពាំងធំទេ?

ម៉ាលី ៖ មិនមែនត្រពាំងធំទេ ប៉ុននៅខាងលើនេះ ពីដើមគេហៅអ្នកស្រុកលើៗម៉ាជួរខ្ពករ៉ុនដំណាក់ ស្នួល លើនេះ ។ នឹងរាប់អាននឹងនៅសល់តែមួយនឹងទេ មួយនឹងគេមកជួបគ្នានៅកន្លែងនឹង ទៀត ។

ដានី ៖ ឥឡូវនឹង ស្រុកភូមិនេះ ជាស្រុកកំណើតអ៊ំហើយ?

ម៉ាលី : បាទ! ជាស្រុកកំណើតខ្ញុំនឹង វាសដៃវាសជើងកាប់គាំងពីអត់ឃើញថ្ងៃ ស្រុកនេះមិនមែនមានថ្ងៃមើលឃើញ ។

ដានី : ចុះដូចថាអ្នកស្រុកអ្នកជិតខាង អ្នកអីដូចជារាប់អានគ្នាជិតស្និតអីយ៉ាងម៉េចដែរ?

ម៉ាលី : ហ៊ឺ! អ្នកស្រុកបើគិតពីខ្ញុំម្នាក់អត់អី វាហូរហែលបងប្អូននៅកន្លែងណាដូចកន្លែងណា ។

ដានី : ស្និតស្នាល់យើងរាប់អានគ្នា យើងអត់មានល្អក់កកអី?

ម៉ាលី : អត់មាន ក្រោយយើងចងក្រងជាក្រុមជាអីឲ្យរកស៊ី ។ ចឹងបាននឹកឃើញថា ពិសេសមួយខាងឥណទានគេដាក់លុយមក ៥-៦នាក់ឯងសាមគ្គីគ្នាខ្ចីលុយក្រុម អាអ្នកនេះអត់ អាអ្នក នេះបេះជួយគ្នា បើឯងធ្វើចឹងកើត ឯងធ្វើក្រុមបានចឹងការសហការគ្នារកស៊ីអីឃើញធូរ ធារដែរ ។

ដានី : បាទ! ចឹងខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំអ៊ំទៀតហើយ ។ ចឹងអ៊ំមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរនាំអ៊ំទៀតទេ?

ម៉ាលី : មានអីថែមទៀត ។

ដានី : អត់ទេ?

ម៉ាលី : អត់មានអីថៃទេ ។

ដានី : ចឹងខ្ញុំអរគុណអ៊ំច្រើនដែលចំណាយពេលឲ្យខ្ញុំសួរនាំពីជីវិតរបស់អ៊ំនេះ បាទ! ខ្ញុំអរគុណអ៊ំច្រើន ។

«ចប់»